# សេចក្តីថ្លែងអំណរគុណ

អង្គការ ផេក សូមថ្លែងអំណរគុណដល់ អង្គការដៃគូពីមុន និង បច្ចុប្បន្ន របស់ខ្លួនទាំងអស់ ដែលបានចំណាយពេលវេលា ដ៏មមាញឹករបស់ពួកគេ សំរាប់ធ្វើការសំភាសន៏ និង ផ្តល់ពតិមានពីអង្គការរបស់ខ្លួន ។

ការស្វែងយល់ និង មេរៀនដែលបានទទួលពី អង្គការផេក និងបទពិសោធន៏របស់ដៃគូខ្លួនអាចជាផលប្រយោជន៏ដល់តួរអង្គទាំងអស់នៅក្នុងវិស័យនានា របស់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ។ យើងបន្តមានមោទនភាពក្នុងការ ធ្វើការជាមួយ អ្នកជំនាន់ទីមួយ នៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា។

# អារម្ភកថា

ការសិក្សានេះពិនិត្យឡើងវិញទៅលើ សមត្ថភាពអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីប៉ាន់ប្រម៉ាណទៅលើចរិតលក្ខណះដែលនាំមកនូវនិរន្តភាពយូរអង្វែងនៃវិស័យក្មេងខ្ចីនេះ។ អង្គការ Pact បានជួយគាំទ្រដល់អង្គការជាង៤0 តាំងពីពាក់កណ្តាល ឆ្នាំ១៩៩២ របាយការណ៏ ឬ ពតិមានរបស់ Pact នេះបង្ហាញពីវិស័យអង្គការមិនមែន រដ្ឋាភិបាល ដ៏ទូលំទូលាយមួយ។ តាមការសិក្សានេះ យើងសង្ឃឹមថាជាការសិក្សាទាន់ពេលវេលាមួយដើម្បីបង្ហាញពីការស្វែង យល់ទៅលើអង្គការទាំងអស់ដែលបន្តរីកចំរើន និង ផ្លាស់ប្តូរ។

ជាមួយនឹងដែនកំណត់នៃការសិក្សានេះវាមានភាពច្បាស់លាស់ដែលថាការសិក្សានេះមិនមែនជាការវាយតំលៃស៊ីជំរៅទៅលើអង្គការនីមួយៗនោះទេ ហើយ ក៏មិនមែនជាការប៉ាន់ប្រមាណគុណភាព ការងាររបស់ពួកគេដែរ។ លើសពីនេះទៅទៀតការសិក្សានេះក៏មិនមែនជាការប៉ាន់ប្រមាណអំពីការចូលរួមរបស់សហគមន៏ហើយក៏គ្មានបំណងធ្វើដូច្នេះដែរ ។ យើងមិនបានធ្វើការកំណត់ដើម្បីពង្រីកនូវវិសាលភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដែលកំពុងបំរើសេវារបស់ពួកគេទេប៉ុន្តែដើម្បីស្វែងរក ថាតើអង្គការទាំងនេះបន្តមានសកម្មភាពល្អយ៉ាងដូចម្តេចមកដល់ពេលបច្ចុប្បន្ននេះ។

ដើម្បីប្រៀបធៀបអង្គការទាំងនេះ យើងបានបង្កើតសន្ទស្សន៍ខ្លះៗ ក្នុងការសំរបសំរួលដល់ការប្រៀបធៀបនេះ។អ្នកអានគួរតែយល់ថាសន្ទស្សន៍ទាំងនេះមិនមានន័យដើម ដោយខ្លួនវាទេប៉ុន្តែវាមានសារះ សំខាន់នៅពេលណាដែលយើងប្រើដើម្បីធ្វើការប្រៀបធៀបតែប៉ុណ្ណោះ។

# មាតិការ


សេចក្តីសង្ខេប.......... ១

១. សេចក្តីផ្តើម.......... ៧

២. គោលបំណងនៃការសិក្សា.......... ៨

៣. វិធីសាស្ត្រ.......... ៨

៤. អ្នកឆ្លើយទៅនឹងការអង្កេត.......... ១០

៥. ភាពអាចសំរេចបាន.......... ១១

៦. ការរកឃើញទូទៅ.......... ១៤

៦.១. រចនាសម្ព័ន្ធគ្រប់គ្រង.......... ១៤

៦.២. ការតស៊ូមតិ និង បណ្តាញការងារ.......... ២០

៦.៣. មូលដ្ឋានមូលនិធិ.......... ២២

៦.៤. គណនេយ្យភាព និង តម្លាភាព.......... ២៨

៦.៥. ស្ថេរភាពនៃការគ្រប់គ្រង.......... ៣១

៦.៦. ទិសដៅកម្មវិធី.......... ៣២

៦.៧. និរន្តភាពរបស់កម្មវិធី.......... ៣៥

៦.៨. ទស្សនៈវិស័យ និង ការជំរុញភាពជាអ្នកដឹកនាំ.......... ៣៦

៦.៩. ធាតុដែលនាំអោយមានជោគជ័យ.......... ៣៩

៧. ការជួយគាំទ្ររបស់ **Pact**.......... ៤០

៨. ឧបសម្ព័ន្ធ.......... ៤៣

៨.១. បញ្ជីឈ្មោះអង្គការដែលបានសំភាសន៍.......... ៤៤

៨.២. ពត៌មានស្តីពី ហិរញ្ញវត្ថុ.......... ៤៦

# សេចក្តីសង្ខេបរួម

ការក្រលេកមើលត្រលប់វិញទៅលើដៃគូ ពីមុននិងបច្ចុប្បន្នចំនួន៤៣ របស់អង្គការ Pact ធ្វើឱ្យគេមើលឃើញ ពីភាព ម្ចាស់ការខ្លួនឯងបាននិងនិរន្តភាពទៅអនាគតរបស់NGO ខ្មែរ ។ គេមើលឃើញថាមានអង្គការចំនួនតែបីទេ (ក្នុងចំណោមអង្គការចំនួន៣១) ដែលត្រូវបិទទ្វារបន្ទាប់ពី ឈប់ទទួលថវិការពី Pact ។ ហេតុផលសំខាន់ដែលបណ្តាលឱ្យគេបិទទ្វារយ៉ាងនេះ គឺបណ្តាលមកពីកង្វះ ការតាំងចិត្តនិងតម្លាភាពនៅក្នុងជួរអ្នកដឹកនាំ ។ បើសិនជាជួរអ្នកដឹកនាំរបស់អង្គការទាំងនេះ មានការតាំងចិត្តខ្ពស់ចំពោះការងារអភិវឌ្ឍន៍ និងចំពោះការរៀនសូត្រពីការងារគ្រប់គ្រង នោះអង្គការទាំងនោះពិត ជានឹងអាចបន្តរហូតរហូតដល់សព្វថ្ងៃនេះ ។

## អភិបាលកិច្ច (Governance)

បណ្តាអង្គការដែល កំពុងបន្តដំណើរការ ទៅមុខកំពុងតែរៀបចំឱ្យមាន រចនាសម្ព័ន្ធគ្រប់គ្រង ដែលមានលក្ខណៈ ឯករាជ្យមួយ ។ ហេតុផលដ៏ធំមួយដែលជំរុញឱ្យគេធ្វើយ៉ាងដូច្នេះគឺគេគិតថាមិនយូរមិនឆាប់ម្ចាស់ អំណោយនឹងទាមទារឱ្យមានយ៉ាងដូច្នេះ ។ តែនៅក្នុងពេលជាមួយគ្នានោះ អ្នកដឹកនាំអង្គការ NGO ជាច្រើនមិនមានភាពប្រាកដនៅក្នុងខ្លួនចំពោះតួនាទីរបស់ក្រុមប្រឹក្សាភិបាល ហើយមានការពិបាកនៅក្នុងការរកឱ្យបាននូវបេក្ខជនដែលមានសមត្ថភាពនិងមានចិត្តចង់ចូលរួម ។ អង្គការខ្លះបានបង្កើតក្រុមប្រឹក្សាភិបាលបានហើយ តែត្រូវរំលាយទៅវិញដោយសារ ក្រុមប្រឹក្សាភិបាលនោះមិនមានប្រសិទ្ធិភាព ។ គេមើលឃើញច្បាស់ថាត្រូវតែមានទំនោរទៅរកការបង្កើតឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងបែបឯករាជ្យនៅទីបំផុតទៅនោះ ។ ប៉ុន្តែដើម្បីធ្វើយ៉ាងដូច្នេះបាន គេត្រូវការជំនួយបន្ថែមពីអង្គការ ដែលជួយទ្រទ្រង់និងការឃើញនិងរៀនសូត្របានខ្លះ ពីសកម្មភាពរបស់ក្រុមប្រឹក្សាភិបាលដែលមានស្រាប់ ។ ទៅអនាគតយូរទៅយើងអាចរំពឹងថាការមានក្រុមប្រឹក្សាភិបាលនឹងជួយបង្កើនប្រសិទ្ធិភាពការងារ ការទទួលខុសត្រូវនិងឈ្មោះល្អដែលអាចឱ្យគេទុកចិត្តបានរបស់ NGO ។ ការមានក្រុមប្រឹក្សាភិបាលនឹងជួយដោះស្រាយវិបត្តិនៅក្នុងការគ្រប់គ្រងជួយនៅក្នុងការទំនាក់ទំនងគ្នាជាបណ្តាញនិង ជួយដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ។

អង្គការដែលនៅក្នុងនោះ អំណាចត្រូវបានបែងចែកស្មើគ្នា ច្រើនជួបប្រទះភាពតានតឹងច្រើន ហើយនៅក្នុងករណីខ្លះក្រុមប្រឹក្សាភិបាលជួយ នៅក្នុងការដោះស្រាយ ការវិវាទគ្នា ។ នៅក្នុងពេលសំភាសន៍នាយកស្ថាបនិកមួយចំនួនបង្ហាញពីចេតនាចង់លាឈប់ ឬ ទៅរកការងារផ្សេងដែលមានលក្ខណៈប្លែក ហើយទាមទារនូវសមត្ថភាពខ្ពស់ ។ ទោះបីជាពីដំបូង គេមានការសង្ស័យចំពោះអត្ថប្រយោជន៍នៃ

វចនាសម្ព័ន្ធនេះក្តី ក៏គំនិតនៃការបង្កើតឱ្យមានក្រុមប្រឹក្សាភិបាលយកធ្វើជាយន្តការដែលធានាដល់ការបន្តចក្ខុវិស័យរបស់គេនោះ ឃើញថាធ្វើឱ្យគេមានការចាប់អារម្មណ៍ខ្លាំង ។

## ការតស៊ូមតិ និង បណ្តាញការងារ (Networking and Advocacy)

ការភ្ជាប់គ្នាជាបណ្តាញ គឺជាជំនាញ ដ៏សំខាន់មួយដែលធ្វើឱ្យ NGO អាចរៀនសូត្រពីគ្នាមើលឃើញពីឱកាសសំរាប់ធ្វើការសហការណ៍គ្នា ហើយទំនាក់ទំនងជាមួយនឹងអ្នកផ្តល់ជំនួយ ។ ការតស៊ូមតិបោះជំហ៊ានមួយជំហ៊ាន ទៅហួសការភ្ជាប់គ្នាជាបណ្តាញ ហើយធ្វើឱ្យ NGO អាចចាប់ផ្តើមនិយាយ ឡើងជួសមុខឱ្យក្រុមឬបញ្ហាមួយ ដោយក្លាយទៅជាអ្នកជំរុញ ឱ្យមានការផ្លាស់ប្តូរ ។ រួមគ្នាទៅការភ្ជាប់គ្នាជាបណ្តាញ ហើយនិងការតស៊ូមតិគឺជាកត្តា សំខាន់សំរាប់ធានាដល់និរន្តភាពផង ឯករាជ្យភាពផងរបស់ NGO ខ្មែរ ។

នៅក្នុងរយៈពេល៨ឆ្នាំកន្លងទៅនេះ ដៃគូរបស់ Pact សំរេចបានលទ្ធផលគួរឱ្យកត់សំគាល់នៅក្នុងប្រការទាំងពីរនេះ ។ គេអាចមើលឃើញជោគជ័យនេះតាមរយៈ បណ្តាញផ្សេងៗដែលគេចូលរួមនិង បញ្ហាផ្សេងៗដែលគេបានតស៊ូមតិទៅលើ ។ ដូចដែលគេបានរំពឹងមក អង្គការដែលផ្តោត សំខាន់ទៅលើបញ្ហានិងសិទ្ធិកំពុងតែ ពង្រឹងជំនាញកាន់តែខ្ពស់ ឡើងលើការតស៊ូមតិ ។ អង្គការដែលធ្វើការផ្នែកអភិវឌ្ឍន៍សហគមន៍និងជនបទ (CD) កំពុងតែធ្វើការងារតស៊ូមតិខ្លះនៅតាមថ្នាក់មូលដ្ឋាន ប៉ុន្តែសកម្មភាពទាំងនេះមានកំរិតព្រំដែន ។ ដើម្បីធានាឱ្យមានអាយុតទៀត និង ឯករាជ្យភាពរបស់ខ្លួន NGOខ្មែរ ត្រូវបន្តពង្រឹង សមត្ថភាពរបស់គេនៅក្នុងការភ្ជាប់បណ្តាញនិងតស៊ូមតិលើបញ្ហានានា ជាពិសេសដើម្បីធ្វើខ្លួនគេឱ្យលេចធ្លោឡើង ពិព្រោះថាមានការប្រកួតប្រជែងគ្នាច្រើនដើម្បីដណ្តើមយកថវិកាដែលមានកំណត់នៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល រិតតែមានការកើនឡើង ។

## មូលដ្ឋានមូលនិធិ (Funding Base)

NGO ដែលទ្រទ្រង់ដោយ អង្គការ Pactអាចមានជីវិតបន្ត ទៅទៀតពីព្រោះគេទទួលបានការឧបត្ថម្ភថវិការរាល់ឆ្នាំ ។ នៅក្នុងន័យនេះយើងអាចនិយាយថា រហូតមកទល់នឹងពេលនេះមានថវិការគ្រប់គ្រាន់ ។ ការស្រាវជ្រាវនៅក្នុងឆ្នាំ ១៩៩៩ទៅលើថវិការដែលផ្តល់ឱ្យដោយម្ចាស់អំណោយបានបង្ហាញឱ្យឃើញថាថវិការដែលផ្តល់ទៅឱ្យ NGO បន្តកើនឡើងរាល់ឆ្នាំ[១] ។ ប៉ុន្តែ ម្ចាស់អំណោយទាំងនេះ

[១] សៀវភៅមគ្គុទេសន៍ធនធានសំរាប់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ឆ្នាំ ១៩៩៩ ដោយអង្គការពន្លក

បានសំដែងឱ្យឃើញថាគេកំពុងតែផ្តល់ថវិការដល់អង្គការដោយគិតជាមធ្យមចំនួន៣០%តិចជាងចំនួនអង្គការដែលគេបានជួយ កាលពី៥ឆ្នាំមុន គឺមានន័យថាមានថវិការច្រើនសំរាប់ផ្តល់ទៅឱ្យអង្គការ ចំនួនតិចនោះ ។

ការពិនិត្យឡើងវិញទៅលើប្រវត្តិនៃការផ្តល់ថវិការ ដល់អង្គការចំនួន២៩ ក្នុងចំណោមអង្គការជាដៃគូរបស់ Pact ពីមុនមកនិងនៅក្នុងពេលបច្ចុប្បន្នចំនួន៤៣ សឱ្យឃើញនិន្នាការផ្សេងៈ

- NGO ដែលធ្វើការងារផ្តោតទៅលើផ្នែកសិទ្ធិនិងបញ្ហា មានភាពងាយស្រួលខ្លះនៅក្នុងការរកថវិការ
- កំរិតនៃថវិការដែលផ្តល់សំរាប់អង្គការដែលធ្វើការផ្នែកអភិវឌ្ឍសហគមន៏ឃើញថាមានការថយចុះ ។
- NGO ខ្លះដែលធ្វើការផ្នែកអភិវឌ្ឍន៏កាន់តែងាកច្រើនទៅរកការពឹងពាក់លើចំណូលដែលបានមកពីការប្រាក់ឥណទាន ។
- អង្គការសមាជិក និងអង្គការបណ្តុះបណ្តាល/ទ្រទ្រង់ នៅបន្តពឹងផ្អែកលើលុយអំណោយជាជាងលើថ្លៃសេវាកម្ម ។
- អង្គការនិស្សិត/អ្នកស្ម័គ្រចិត្តអាចរកចំណូលបានដោយការបើកថ្នាក់បង្រៀនដែលយកថ្លៃថោកនៅចុងទសវត្សទី ៩០ ប៉ុន្តែនៅក្នុងឆ្នាំថ្មីៗនេះចំណូលនេះមានការថយចុះ ។

និន្នាការនៅក្នុងការផ្តល់ ថវិការនៅពេលបច្ចុប្បន្ននេះ គឺជាកង្វល់ធំមួយសំរាប់អង្គការ ដែលធ្វើការលើផ្នែកអភិវឌ្ឍសហគមន៍ ។ នៅពេលបច្ចុប្បន្ននេះ មិនមានយន្តការនៅ នឹងមូលដ្ឋាននៅក្នុងការផ្តល់ថវិការដល់ NGO តូចៗដែលធ្វើការផ្នែកអភិវឌ្ឍសហគមន៏នៅតាមតំបន់ដាច់ស្រយ៉ាលនោះទេ ហើយអនាគតទៅមុខរបស់អង្គការទាំងនេះកំពុងតែប្រឈមនឹងគ្រោះថ្នាក់ ។ គេត្រូវការយកចិត្តទុកដាក់ជាពិសេសដល់ការរៀបចំយុទ្ធសាស្ត្រថ្មីល្អមួយ ដែលបន្តលើកទឹកចិត្ត ដល់ការកកើតជាបន្តនូវ សកម្មភាពផ្តួចផ្តើមនៅក្នុងស្រុក ។ តាមការសង្ស័យរបស់យើង បើសិនជាមិនមានថវិការច្រើនសំរាប់ NGO ដែលធ្វើការផ្នែកអភិវឌ្ឍន៏សហគមន៏នៅពេលអនាគតនោះទេ នោះអង្គការទាំងនេះត្រូវតែធ្វើការ អប់រំសហគមន៏អំពីកម្មវិធីរបស់គេ ហើយធ្វើការរៃអង្គាសប្រាក់នៅ នឹងមូលដ្ឋានរបស់គេតែម្តង ។ គេត្រូវការរៀនផងដែរពីយុទ្ធសាស្ត្រថ្មីៗនៅក្នុងការរៃអង្គាស ដូចជាសាខាអង្គការព្រះពុទ្ធសាសនាសំរាប់ការអភិវឌ្ឍន៏នៅLowel នៅក្នុងរដ្ឋ Massachusetts ដែលឧបត្ថម្ភដល់ការបើកអ៊ិនធ័រនែត សំរាប់ក្មេងៗនៅបាត់ដំបង ។ មិនថាអង្គការណាជាអង្គការណាទេ NGO ទាំងអស់និយាយថានិរន្តភាព ផ្នែកថវិការនៅតែ ជាកង្វល់ធំមួយរបស់គេនៅពេលដែលគេចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំនិមួយៗនូវការរកប្រាក់សំរាប់គំរោង តៗទៅទៀត ។

## គណនេយ្យភាព និង តម្លាភាព (Accountability and Transparency)

NGOខ្មែរកំពុងតែរៀនសូត្របានពីសារៈសំខាន់នៃការទទួលខុសត្រូវនិងតម្លាភាព។ ពិតហើយថាការគាប សង្កត់ពីមុនៗមកឱ្យ អនុវត្តលើចំណុចពីរនេះ គឺចេញមកពីម្ចាស់អំណោយតែ NGO ជាច្រើនបានដើរតាម គោល ការណ៍ដោយខ្លួនគេ ហើយថែមទាំងយល់ពីសារៈសំខាន់របស់វាថែមទៀតផង ។ ឧទាហរណ៍ ពីដំបូងមកNGO មានការថប់បារម្ភចំពោះការចុះត្រួតពិនិត្យមើលការចាយវាយតែ NGOដែលទទួល នូវការចុះពិនិត្យមើលការចាយវាយ ជាទៀងទាត់នោះមានការយល់ឃើញ ធម្មតាចំពោះដំណើរការត្រួត ពិនិត្យនោះ ។ ប៉ុន្តែការត្រួតពិនិត្យនេះ អាចធ្វើទៅបានលុះ ណាតែម្ចាស់ អំណោយបញ្ចូលការចំណាយ សំរាប់ការ ត្រួតពិនិត្យនោះទៅក្នុងខ្ទង់ថវិការរបស់ដៃគូខ្លួន ។

ដោយហេតុថាថវិការនៅ តែពឹងផ្អែកជាសំខាន់ទៅលើម្ចាស់អំណោយ វាមិនមែនជាការអ្វីប្លែកទេដែលថា ការទទួលខុសត្រូវគឺផ្តោតសំខាន់ជាមួយនឹងម្ចាស់អំណោយ។ NGO ភាគច្រើនរៀបចំរបាយការណ៍ ប្រចាំ ឆ្នាំ ជាភាសាអង់គ្លេស ហើយផ្ញើឱ្យតែម្ចាស់អំណោយរបស់គេ តែប៉ុណ្ណោះ ។ មានNGOចំនួនតិចទេដែល ធ្វើការជំរាបទៅ សហគមន៍គោលដៅរបស់គេឬ អ្នកទទួលផលរបស់គេជាភាសាខ្មែរស្តីពីសកម្មភាព របស់ គេ ។ បើ NGO មិនទទួលបានការជួយពីសហគមន៍របស់គេទេ នោះNGO នោះប្រហែលមិនធ្វើអ្វីដែល បញ្ជាក់ពីការទទួលខុសត្រូវ របស់ខ្លួនចំពោះសហគមន៍ទេ ។ អ្វីដែលគេភាគច្រើននឹកមិនដល់នោះគឺថា បើគេមិនជំរាបប្រាប់ ទៅសហគមន៍របស់គេហើយ ធ្វើអ្វីដែលសឱ្យឃើញពីការទទួល ខុសត្រូវរបស់គេនៅ ក្នុងលក្ខណៈណាមួយនោះទេ នោះគេនឹងមិនអាចបំផុសបាននូវការគាំទ្ររបស់សហគមន៍ទេ ។

## ស្ថេរភាពនៃការគ្រប់គ្រង (Management Stability)

ដូចអ្នកដែលធ្លាប់ស្គាល់ពិចលនា NGOខ្មែរដឹងហើយ ការរីកចំរើនឡើងនៃចលនានេះ មិនមែនដំណើរការ ទៅដោយមិនមានវិបត្តិ និងការប្រេះឆាដ៏ច្រើននោះទេ ។ ទោះបីជាមានការពិបាកនៅក្នុង ការរៀបរាប់ឱ្យ បានច្បាស់ក្តី មើលទៅឃើញមានវិបត្តិមិនច្រើនទេនៅក្នុងចំណោម អង្គការជាដៃ គូរបស់ អង្គការPact ។ ការនេះប្រហែលមកពីអង្គការ Pact ជួយនៅក្នុងការចរចារលើជំលោះ និងលើការ គ្រប់គ្រង ។ជាទូទៅ ការសិក្សាអង្កេតសន្និដ្ឋានថាការ វិវាទច្រើនកើតមាននៅក្នុង រង្វង់អង្គការ ដែលគ្រប់គ្រងដោយ នាយក ស្ថាបនិកជាជាងនៅក្នុងអង្គការដែល នាយកត្រូវបានជ្រើសតាំងឡើង ទោះបីជាថានៅពេល ដែលអំណាច នៅផ្តុំនៅថ្នាក់កណ្តាល មិនសូវមានឱកាសឱ្យគេសំដែង ចេញនូវការ ជំទាស់ក្តី ។គេអាចគិតថា ការជំទាស់ ច្រើនត្រូវបានគេលើកឡើងនៅពេលដែលអំណាចត្រូវ បានបែងចែកនៅក្នុងលក្ខណៈស្មើៗគ្នាហើយនៅក្នុង សភាព នេះឯងដែលគេត្រូវការក្រុមប្រឹក្សាភិបាលដើម្បីជួយ ដោះស្រាយការវិវាទគ្នា ។

## ទិស និង និរន្តរភាពរបស់កម្មវិធី (Program Directions and Sustainabiltiy)

NGO ខ្មែរលែងជាក្រុមមួយដែលមានលក្ខណៈសុទ្ធតែគ្នាឯងទៀតហើយ ហើយប្រភេទផ្សេងៗកំពុងតែកកើតឡើងនៅក្នុងល្បឿនខុសៗគ្នា ។ NGO ដែលផ្តោតទៅលើបញ្ហានិងការតស៊ូមតិមើលទៅហាក់មានការយល់ដឹង មានការឆ្លើយតបរហ័ស និង មានគំនិតច្នៃប្រឌិតច្រើន។ អង្គការផ្នែកគាំទ្រ (Support Organization) ក៏មើលទៅឃើញថា មាំទាំដែរ ទោះបីជាថាគេនៅត្រូវការ បន្តកែលំអ សេវារបស់គេជាប្រចាំតទៅទៀតហើយនៅបន្តពឹងផ្អែកលើម្ចាស់អំណោយក្តី ។ អង្គការផ្នែកអភិវឌ្ឍន៍ សហគមន៍បានរៀន នូវជំនាញនៅក្នុងការអនុវត្តកម្មវិធី ប៉ុន្តែមិនសូវចេះគ្រោងរៀបចំកម្មវិធីទេៈ បន្តិចម្តងៗ កម្មវិធីអភិវឌ្ឍន៍ សហគមន៍ចាប់ផ្តើមមើលទៅដូចតែគ្នា ។ វាសនានៃអង្គការនិស្សិត នៅមិនទាន់ច្បាស់នៅឡើយ ។

ពិតមែនហើយថានិរន្តភាពនៃ កម្មវិធីកំពុងតែក្លាយជាកង្វល់កាន់តែធំសំរាប់ NGO តែផ្នែក សមត្ថភាពនៅក្នុងផ្នែកនេះនៅទាបនៅឡើយ ។ ច្រើនតែNGOធំៗដែលធ្វើការផ្នែក អភិវឌ្ឍន៍ សហគមន៍ទេដែលកំពុងតែចាប់ផ្តើមបង្វែរការគ្រប់គ្រងលើគំរោង ទៅឱ្យក្រុមមនុស្សនៅនឹងសហគមន៍ ។ សមត្ថភាពនៅក្នុងការគ្រោង អនុវត្តនិងរក្សាបាននូវកម្មវិធីដែលឆ្លើយតបបានល្អ គឺជាការបង្ហាញ ពីភាពចាស់ទុំរបស់ NGO ។

សមត្ថភាពទាំងនេះនៅតែមានសារៈសំខាន់ណាស់សំរាប់និរន្តភាពរបស់អង្គការ ហើយកាន់តែមានសារៈសំខាន់ទៀត បើសិនជាថវិកាសំរាប់NGO ដែលធ្វើការលើផ្នែកអភិវឌ្ឍន៍សហគមន៍កាន់តែមានតិចទៅ។ បើសិនជាមានការជំរុះបណ្តាNGO ផ្នែកអភិវឌ្ឍន៍សហគមន៍ នោះអង្គការដែលមាន គំនិតច្នៃប្រឌិត នឹងមានវាសនាអាចរស់តទៅទៀតបាន ។

## ទស្សនៈវិស័យនិងការជំរុញភាពជាអ្នកដឹកនាំ (Vision and Fostering Leadership)

ដើម្បីវាយតំលៃមើលថាតើ NGO កំពុងតែរក្សាភាពដឹក នាំដែលនឹងនាំទៅរកការគ្រប់គ្រងល្អ កម្មវិធីថ្មីហើយ ល្អ ហើយនិងសេវាកម្មប្រកប ដោយគុណភាពនោះ យើងបានជ្រើសរើសសន្ទស្សន៍ដើម្បីធ្វើការវាស់ស្ទង់ពិករិតដែលប្រធាន NGO ធ្វើការប្រគល់ការងារទទួលខុសត្រូវរបស់គេ សង្កត់ធ្ងន់លើជំនាញលើភាសាអង់គ្លេស ហើយនិងផ្តល់ឱកាសចុះសិក្សា (Exposure Opportunities) ។

ទោះបីជាមិនអាចធ្វើការវិភាគឱ្យបានច្បាស់លាស់ ដូចស្ថិតិក្តី តែការពិនិត្យមើលឡើងវិញខ្លះៗរបស់យើងបង្ហាញថាNGOដែលយើងចាត់ទុកថាបានទទួល ជោគជ័យខ្លាំងជាងគេនោះ គេសង្កត់ធ្ងន់ទៅលើជំនាញ

លើភាសាអង់គ្លេស ហើយនិងទស្សនកិច្ចសិក្សានៅឯបរទេសសំរាប់បុគ្គលិករបស់គេ។ យើងក៏បានសង្កេតឃើញផងដែរថា អង្គការដែលមានភាពចាស់ទុំ ផ្តោតទស្សនៈរបស់គេទៅលើការ លើកកំពស់ការអនុវត្តការងារនៃក្រុមគោលដៅជាជាងលើទស្សនៈធំទូលាយដែលសំដៅលើការកែលំអស្ថានភាពនៅក្នុងប្រទេសកម្ពុជា ។

## ធាតុដែលនាំអោយមានជោគជ័យ (Elements of Success)

នៅពេលដែលយើងសួរទៅ NGOថាអ្វីទៅដែលជាកត្តានៃជោគជ័យរបស់គេ ចំលើយដែលយើងច្រើនតែទទួលមកវិញនោះគឺទាក់ទងទៅនឹង ការគ្រប់គ្រងល្អ សមត្ថភាពនិងការតាំងចិត្តរបស់បុគ្គលិកសមត្ថភាពនៅក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៏ ហើយនិងការបញ្ចូលសមាជិកសហគមន៏ទៅក្នុងការធ្វើផែនការ ។

## ការជួយគាំទ្ររបស់អង្គការ ផេក (Pact Support)

NGO ដែលទទួលការជួយរបស់Pact ឱ្យតំលៃដល់ការជួយលើការពង្រឹងសមត្ថភាពលើសអ្វីទាំងអស់ពិសេសទាក់ទងទៅនឹងការសរសេរសំណើរនិងរបាយការណ៏ការធ្វើផែនការ និង ការគ្រោងរៀបចំកម្មវិធី។ របៀបគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គការ Pact ត្រូវបានបណ្តារ NGO កោតសរសើរ ពិសេសអង្គការដែលអាចប្រើរបៀបនោះជាមួយនឹងម្ចាស់អំណោយផ្សេងទៀត។ គេសំដែងនូវការត្រេកអរចំពោះការជួយផ្នែកហិរញ្ញវត្ថុ ដែលបានធ្វើឱ្យគេអាចដំណើរការកម្មវិធីទៅមុខបាន ។ ការជួយផ្សេងទៀតដែលមានតំលៃដែរនោះហើយដែលយើងបានដឹងគឺរួមមាន ការបញ្ជូនមកនូវអ្នកស្ម័គ្រចិត្ត ទីប្រឹក្សាបច្ចេកទេស និងការផ្តល់ជំនួយបច្ចេកទេសនៅក្នុងការពង្រឹងអង្គការ ។

# តើអនាគតនឹងទៅជាយ៉ាងដូចម្តេច?

## អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ~ ការអភិវឌ្ឍន៍អង្គការ ~

## ឯករាជ្យភាព និង និរន្តរភាព

### ១~ សេចក្តីផ្តើម

អង្គការ Pact បានចាប់ដំណើរការ ការងាររបស់ខ្លួនក្នុងប្រទេសកម្ពុជានាខែតុលា ឆ្នាំ ១៩៩១ ដោយបានទទួលមូលនិធិគាំទ្រពី USAID ដើម្បីចាប់ផ្តើមគំរោងឈ្មោះ សហគមន៍ចែកចាយគំរោងកម្ពុជា (CCOP) ។ ជាដំបូងអង្គការ Pact បានផ្តល់ការគាំទ្រទៅដល់អង្គការអន្តរជាតិចំនួន១០ ដែលក្នុងនោះមាន ៣ ជាអង្គការកម្ពុជា-អាមេរិកាំង ធ្វើការទៅលើការផ្តល់សេវាកម្មនានា នៅក្នុងប្រទេសអាមេរិកដើម្បី អនុវត្តគំរោងដែលបំរើ ផលប្រយោជន៍ដល់ស្ត្រី ជនពិការដោយសារសង្គ្រាម និង ក្រុមដែលងាយទទួលរងគ្រោះផ្សេងៗទៀត នៅក្នុងប្រទេសកម្ពុជា ។ អង្គការជាច្រើននៃអង្គការខាងលើនេះ បានក្លាយជាអង្គការ មិនមែនរដ្ឋាភិបាលកម្ពុជា ។

អង្គការ Pact គឺជាអង្គការផ្តល់ជំនួយ លើកដំបូងមួយ ក្នុងចំណោមអង្គការផ្តល់ជំនួយនានា ដែលបានគាំទ្រអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាក្នុងស្រុក នៅកម្ពុជា ។ ចាប់តាំងពីមានការចាប់ផ្តើម កម្មវិធីគាំទ្រអង្គការក្នុងស្រុក (Local Initiatives Support Program) នាខែ កញ្ញាឆ្នាំ ១៩៩២មក អង្គការ Pact បានផ្តល់ថវិការ និង ជំនួយផ្សេងៗ ដល់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ជាង ៤០ ដែលធ្វើការទៅលើវិស័យអភិវឌ្ឍន៍សហគមន៍ ឥណទាន ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំសុខភាព ការពន្យាកំណើត ការយល់ដឹងអំពី HIV/AIDS ការតស៊ូមតិ និង សិទ្ធិមនុស្ស[2] ។ អង្គការ Pact ក៏បានជំរុញផងដែរដល់ការបង្កើតអង្គការផ្នែកគាំទ្រដែលផ្តល់សេវាកម្មផ្សេងៗទៅដល់បណ្តារ អង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ។

មូលនិធិជំនួយភាគច្រើនគឺសំរាប់គាំទ្រទៅដល់ស្ថាប័ន និងកម្មវិធីសំរាប់រយៈពេលវែង ។ ប៉ុន្តែនៅក្នុងករណីខ្លះ មូលនិធិជំនួយត្រូវបានផ្តល់ដើម្បីគាំទ្រ ក្នុងរយៈពេលខ្លី ឬព្រឹត្តិការណ៍ជាក់លាក់ផ្សេងៗ ។ ដោយសារៈប្រយោជន៍ នៃការធ្វើអង្កេតនេះគឺដើម្បីយល់ដឹងឱ្យកាន់តែទូលំទូលាយ ស្តីអំពីសមត្ថភាពអង្គការក្នុងចំណោម

អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដូច្នេះអង្គការដែលបានទទួល មូលនិធិជំនួយចំនួនតិចតួច ក៏ត្រូវបានរាប់បញ្ចូល នៅក្នុងសំណាកដែរ ។

## ២. គោលបំណងនៃការសិក្សា

គោលបំណងនៃការសិក្សានេះគឺផ្តោតទៅលើអង្គការចំនួន ៤៣ ដែលទទួលមូលនិធិពីអង្គការ Pact នាពេលបច្ចុប្បន្ន និងកាលពីអតីតកាល ដើម្បីធ្វើការកំណត់អំពីចរិតលក្ខណៈដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍អង្គការនៅក្នុងចំណោម អង្គការមិនមែនរដ្ឋាភិបាល ជាដៃគូររបស់អង្គការ Pact ដែលធ្វើការ ដើម្បីឈានទៅរកឯករាជ្យភាព និង និរន្តន៏ភាពរបស់អង្គការ ។ការធ្វើអង្កេតនេះត្រូវបានធ្វើឡើងនា ចន្លោះខែមេសា និង កក្កដា ឆ្នាំ ២០០០ ។ តាមលក្ខខ័ណ្ឌនៃការយល់ព្រមគ្នា (Terms of References) ត្រូវការសិក្សាស៊ីជំរៅអោយបាន ២៥ % (១០ អង្គការ) នៃអង្គការដៃគូរបស់ Pact ។ ទំរង់អង្គការ (Organizational Profiles) ត្រូវបានបំពេញចប់សំរាប់អង្គការដៃគូចំនួន៣២។ អង្គការចំនួន២៩ ក្នុងចំណោមអង្គការទាំង៣២ នេះបានផ្តល់ពតិមានទាក់ទងនឹង ហិរញ្ញវត្ថុ។

## ៣. វិធីសាស្ត្រ

នៅក្នុងពេលសរសេររបាយការណ៏នេះ ឧបករណ៏វាស់វែងសមត្ថភាពអង្គការ មួយចំនួនត្រូវបានបង្កើតឡើងឬកែសំរួលសំរាប់ការប្រើប្រាស់នៅប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយការគាំទ្រភាគច្រើនទៅដល់ដៃគូរបស់អង្គការ Pact បានកើតឡើងនៅក្នុងកំលុងដើមឆ្នាំ នៅពេលដែលការគាំទ្រ ផ្តែកកសាងសមត្ថភាពដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នៅប្រទេសកម្ពុជា នៅតែស្ថិតក្នុងដំណាក់កាល ដំបូងនៅឡើយ ហើយការប៉ាន់ប្រមាណសមត្ថភាពអង្គការគឺនៅមិនទាន់មានការរៀបចំអោយបានត្រឹមត្រូវនៅឡើយទេ ។ លើសពីនេះទៅទៀត ឧបករណ៏ភាគច្រើនដែលបានបង្កើតឡើងមានភាពសាំញ៉ាំ និង លំបាកយកមកប្រើប្រាស់អោយបានទូលំទូលាយ។ ម្យ៉ាងទៀត ឧបករណ៏ទាំងនេះ មិនបានបង្កើតដោយរួមបញ្ចូលអំពីបញ្ហា និរន្តភាព និង ឯករាជ្យភាពទេ។

បន្ទាប់ពីការរំលឹកឡើងវិញ នូវចំនួនឧបករណ៏វាស់វែងសមត្ថភាពអង្គការ ដែលមានរួមបញ្ចូល មានឧបករណ៏ប៉ាន់ប្រមាណការគ្រប់គ្រងអង្គការ (MAT) និងការប៉ាន់ប្រមាណសមត្ថភាពអង្គការ (OCA) ដែលសន្ទស្សន៍

ទាំងអស់ត្រូវបានបង្កើតឡើងដោយអង្គការដៃគូរហើយអ្នកស្រាវជ្រាវមានបំណងធ្វើការកំណត់ចំនួនសន្ទស្សន៍សមស្របដែលត្រូវយកមកប្រើដើម្បីប្រៀបធៀបអង្គការដៃគូររបស់ Pact ។

នៅក្នុងការពិភាក្សាជាមួយ នឹងសហសេវិកដែលរួមការងារជាមួយគ្នា មុននឹងធ្វើការជ្រើសរើស សន្ទស្សន៍ផ្សេងៗ គេបានសំដែងនូវការព្រួយបារម្ភណ៏ថាជាធម្មតាអង្គការជាដៃគូរ និង ភ្នាក់ងារផ្តល់មូលនិធិមានការរំពឹងទុកផ្សេងៗពីគ្នា ហើយការបកស្រាយ និយមន័យក៏មានភាពខុសៗគ្នាដែរ ។ ការពិភាក្សាមួយដែលអាចយកជាការបាន បានលើកឡើងថា ដើម្បីធ្វើការសង្កេតអំពីនិរន្តភាព និងឯករាជ្យភាព នោះជាដំបូង យើងត្រូវយល់ពីទស្សនះដែលយើងកំពុងចាប់ផ្តើម ។ ជាការឆ្លើយតប វាមានសារៈសំខាន់ដោយចង្អុលបញ្ជាក់ថាអង្គការមិនមែនរដ្ឋាភិបាលភាគច្រើន មានទស្សនះបែបលោកខាងលិចនៅកម្ពុជា ហើយមូលនិធិភាគច្រើន (រហូតដល់ ៨៨%) គឺបានមកពីម្ចាស់មូលនិធិ ដែលជាប្រទេសលោកខាងលិច ទោះបីជាមានសមាគមសង្គមស៊ីវិលដទៃទៀតនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ[៣] ក៏ដោយ។ ដូច្នេះមានតែការពិភាក្សាដោយសំរបសំរួលដើម្បីប្រើប្រាស់ខ្នាតសន្ទស្សន៏គំរូ តាមបែបលោកខាងលិចដើម្បីនិរន្តភាព ។ លើសពីនេះទៅទៀត ក្នុងខណះពេលដែលម្ចាស់ជំនួយកាន់តែផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើ និរន្តភាពអង្គការ និង កម្មវិធីក៏រិតនៃការពឹង ផ្អែកខ្ពស់របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទៅលើមូលនិធិអន្តរជាតិ និងកង្វះសន្តិសុខ មូលនិធិរយះការ យូរអង្វែង មានន័យថា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ភាគច្រើនបន្តស្ថិតនៅក្នុង ដំណាក់កាលមួយដែល ពួកគេផ្តោតទៅលើនិរន្តភាពហិរញ្ញវត្ថុ[៤] ។ ដើម្បីធានាអោយបាននូវការបន្តជួយគាំទ្រ ផ្នែកហិរញ្ញវត្ថុអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាចាប់អារម្មណ៏ក្នុងការតំរូវទៅតាមការរំពឹងទុករបស់ម្ចាស់មូលនិធនៃប្រទេសលោក ខាងលិច ។

ដោយហេតុថាមានបញ្ហាទាំងនេះស្រាប់នោះវិស័យសមត្ថភាពអង្គការដូចខាងក្រោមត្រូវបានកំណត់ជាកត្តាគន្លឹះ សំរាប់និរន្តភាពះ

- រចនាសម្ព័ន្ធគ្រប់គ្រង
- ការតស៊ូមតិ និងបណ្តាញការងារ
- មូលដ្ឋានមូលនិធិ (រួមបញ្ចូលទាំងការបង្កើនប្រាក់ចំណូល)

- គណនេយ្យភាព និងតម្លាភាព
- ស្ថេរភាពនៃការគ្រប់គ្រង
- ទិសដៅកម្មវិធី
- និរន្តភាពកម្មវិធី
- ជំរុញភាពជាអ្នកដឹកនាំ និង ទស្សនៈយូរអង្វែង

ដូចនេះអ្នកស្រាវជ្រាវបានឆ្លើយទៅនឹងសំណួរដូចខាងក្រោមនេះ :

- តើដៃគូរអង្គការ Pact បានអនុវត្តទៅលើវិស័យសមត្ថភាពអង្គការ បានដល់កំរិតណា ?
- តើអ្វីជាទស្សនៈវិស័យសំរាប់និរន្តភាពរបស់គេ ?
- តើមានកត្តាអ្វីខ្លះ ដែលចូលរួមចំណែកដល់ ទស្សនៈវិស័យវិជ្ជមាន ?
- តើពួកគេកំពុងបង្កើនឯករាជ្យភាព នៅក្នុងការកំណត់ទិសដៅកម្មវិធី បានក្នុងកំរិតណា ?
- តើអ្វីខ្លះដែលបានមកពីការរួមវិភាគទានដ៏មានតំលៃបំផុត ធ្វើឡើងដោយអង្គការ Pact ?
- តើមានមេរៀនអ្វីខ្លះដែលអាចទទួលបានពីបទពិសោធន៏របស់អង្គការ Pact ?

វិធីសាស្ត្រដែលបានប្រើគឺ ការពិនិត្យឡើងវិញនូវឯកសារនានា ដែលមានស្រាប់របស់អង្គការ Pact ដែល ទាក់ទងទៅនឹងអង្គការនានា បន្ទាប់មកយើងធ្វើសំភាសន៏ សមាជិក ចំនួនមួយ ឬលើសពីនេះនៃអង្គការជាដៃគូរ ។ ក្រុមសំភាសន៏យើង ក៏បានធ្វើការពិភាក្សាតាមក្រុមទៅលើប្រធានបទជាក់លាក់ ហើយក្នុង ឱកាសនោះដែរ យើងក៏បានលើកយក ប្រធានបទដូចគ្នាទៅពិភាក្សាជាមួយ អង្គការមិនមែនរដ្ឋាភិបាល ផ្សេងៗទៀតដើម្បី ប្រមូល ទស្សនៈរបស់ពួកគេ ។

## ៤ .អ្នកឆ្លើយទៅនឹងការអង្កេត

ក្រុមសំភាសន៏បានស្រាវជ្រាវទៅលើអង្គការទាំង ៤៣ ដើម្បីស្វែងរកថាពួកគេស្ថិតនៅក្នុងតំណាក់កាលណា ឥឡូវនេះ។ បញ្ជីឈ្មោះដៃគូអង្គការ Pactទាំងអស់ដែលបានធ្វើសំភាសន៏ គឺសូមមើលនៅក្នុងឧបសម្ព័ន្ធ A ក្នុងចំណោម ៤៣ អង្គការគឺមានអង្គការចំនួន ៣ ឈប់ដំណើរការ និងអង្គការចំនួន ១ បានបដិសេធមិនព្រម អោយសំភាសន៏ ។ មាន៣២អង្គការត្រូវបានបំពេញចប់សព្វគ្រប់ក្នុងចំណោមអង្គការទាំង ៤៣ ហើយ ២៩

អង្គការ បានផ្តល់ពិតមានស្តីអំពីហិរញ្ញវត្ថុ ទោះបីជា ពតិមានខ្លះនៅដើមឆ្នាំត្រូវបាត់បង់ដោយសារកង្វះខាត ការរៀបចំទុកដាក់ឯកសារឱ្យបានត្រឹមត្រូវ និង បុគ្គលិកមានការផ្លាស់ប្តូរច្រើន ធ្វើអោយមានការបាត់បង់ ឯកសារមួយចំនួន ។ គ្រប់អង្គការទាំងអស់ លើកលែងតែអង្គការមួយចេញ បានយល់ព្រមអោយពតិមាន ហិរញ្ញវត្ថុ ផ្សព្វផ្សាយជាសាធារណៈបាន ចំណែកឯអង្គការសប្បុរស បានផ្តល់តែចំនួនថវិកាក៏ប៉ុន្តែមិនឱ្យផ្សព្វ ផ្សាយ ជាសាធារណៈទេ ។ រាល់អ្នកឆ្លើយតបទាំងអស់បានស្វាគមន៍ ក្រុមសំភាសន៍និងបានបើកទូលាយអំពី ការចែករំលែកពតិមាន ព្រមទាំងការពិភាក្សាទៅលើបញ្ហាផ្សេងៗ ។

## ៥. ភាពអាចសំរេចបាន

ភាគច្រើនបំផុតនៃអង្គការដែលបានគាំទ្រដោយអង្គការ Pact ត្រូវបានបង្កើតឡើងក្នុងកំឡុងឆ្នាំ ១៩៩១ - ១៩៩៤ ហើយអាចនិយាយបានថា ការបង្កើតជំនាន់ដំបូង សំរាប់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ។ ការពិនិត្យមើលឡើងវិញទៅលើអង្គការមិនមែនរដ្ឋាភិបាលក្រៅពីការទទួលខុសត្រូវរបស់អង្គការ Pact បាន បង្ហាញអោយឃើញថា ជំនាន់ទីពីរបានបង្កើតឡើង នៅដើមឆ្នាំ ១៩៩៨ ដែលរួមមានអង្គការមិនមែនរដ្ឋាភិ បាល ផ្នែកអភិវឌ្ឍន៍សហគមន៍ជនបទតូចៗ និង អង្គការ ផ្នែកតស៊ូមតិ និងបណ្តុះបណ្តាល ។

ចាប់ពីខែកក្កដាឆ្នាំ ២000 មានអង្គការចំនួន ៣ ត្រូវបានចាត់ទុកថាមិនបន្តប្រត្តិបត្តិការរបស់ខ្លួន។ អង្គការទាំងនេះរួមមានសមាគមអ្នកបើកបរកម្ពុជា (CCA) គណកម្មាការអភិវឌ្ឍន៍ដើម្បីមិត្តភាព យុវជន ជនបទ (CDFRY) និង សហព័ន្ធពន្លឺខ្មែរ ។ លើសពីលើនេះ ការដែលអាចសំរេចបានដោយអង្គការមួយដែល មានឈ្មោះថា កម្មវិធីស្ត្រីអប់រំជំងឺអេដស៏ខេត្តបាត់ដំបង (BWAP) ត្រូវបានចាត់ទុកជាបញ្ហាធ្ងន់ធ្ងរមួយដោយ សារអង្គការនេះ ត្រូវបានបង្ខំអោយបិទការិយាល័យរបស់ខ្លួន នារយៈពេលប៉ុន្មានខែចុងក្រោយនេះ ។

អង្គការ CCA មានគោលបំណង ផ្តល់សេវាកម្មទៅដល់អ្នកធាក់ស៊ីក្លូ ដោយរួមមាន ជួលស៊ីក្លូក្នុងតំលៃថោក ជួយអ្នកធាក់ស៊ីក្លូដើម្បីទិញស៊ីក្លូ ធ្វើការសំរបសំរួលរកទីកន្លែងស្នាក់នៅ និងការហូបចុក ដែលមានតំលៃថោក ព្រមទាំងធ្វើការអប់រំដល់អ្នកធាក់ស៊ីក្លូ អំពីបញ្ហាផ្សេងៗ ដែលទាក់ទងទៅនឹងច្បាប់ចរាចរ ។ ការគាំទ្ររបស់ អង្គការ Pact គឺផ្តោតសំខាន់ ទៅលើការពង្រឹង សមត្ថភាព អង្គការដល់អង្គការដែលកំពុង អនុវត្តគំរោង HIV/AIDS ធ្វើយ៉ាងណាអោយអ្នកធាក់ស៊ីក្លូ អាចលក់ស្រោមអនាម័យដល់ អតិថិជនរបស់ខ្លួន ។ បុគ្គលិក សំខាន់ៗខ្លះរបស់អង្គការCCA មានការតាំងចិត្តយ៉ាងខ្លាំងចំពោះការងាររបស់ខ្លួន ប៉ុន្តែអង្គការមានដំណើរការ

មិនល្អដោយសារការគ្រប់គ្រងមិនត្រឹមត្រូវពីថ្នាក់ដឹកនាំ ។អង្គការ Pact បានប្រឹងប្រែងព្យាយាមជួយជាជំនួយនៅក្នុងផ្នែកភាពជាអ្នកដឹកនាំ ប៉ុន្តែការតាំងចិត្តរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៅក្នុង CCA មានការខ្វះខាត ។ បន្ទាប់ពីការប្រឹងប្រែង មិនបានទទួលជោគជ័យជាច្រើនលើក ដើម្បីកែលំអរស្ថានភាព អង្គការ Pact បានដកជំនួយរបស់ខ្លួន។ បុគ្គលិកដែលមានការតាំងចិត្តធ្វើការ បានចាកចេញពីអង្គការនេះ ហើយ ពួកគេបានបន្តធ្វើការងារដ៏ល្អជាមួយនឹងអង្គការដទៃទៀត ហើយ ទីបញ្ចប់អង្គការ CCA ត្រូវដួលរលំ ។ ដូចគ្នានឹងអង្គការ CDFRYដែរភាពបរាជ័យរបស់អង្គការCCA អាចជាលទ្ធផលដោយផ្ទាល់មួយដែលទាក់ទងទៅនឹងកង្វះខាតលើការដឹកនាំ និង មិនមានការតាំងចិត្តក្នុងដំណើរការប្រត្តិបត្តិ អោយមានតម្លាភាពចំពោះ អង្គការមិនរកប្រាក់កំរៃ ។

អង្គការ CDFRY បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៩៣ ដោយផ្តល់ការបណ្តុះបណ្តាលជំនាញ ហើយ គឺជាអង្គការមួយក្នុងចំណោមអង្គការដំបូងបំផុតដែលទទួលជំនួយមូលនិធិពីអង្គការ Pact ។ អង្គការ Pactបានជួយផ្តល់ការគាំទ្រទៅលើទស្សនកិច្ចសិក្សាក្នុងប្រទេស ដើម្បីធ្វើអោយអង្គការ CDFRY យល់ដឹងអំពីការគ្រប់គ្រង ការធ្វើផែនការ និងការធ្វើគំរាងកម្មវិធី ព្រមទាំងជួយទិញសំភារៈ សំរាប់ផ្គត់ផ្គង់សំរាប់ដំណើរការកម្មវិធីបណ្តុះបណ្តាល ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលចុះត្រួតពិនិត្យអង្គការនេះ មិនបានធ្វើសេចក្តីរាយការណ៍អំពីបញ្ហាជាច្រើនដែលផ្លាស់ប្តូរ និង ធ្វើអោយភាពជឿទុកចិត្ត និង ភាពជាអ្នកដឹកនាំស្ថិតក្នុងភាពមុន្ទិលសង្ស័យ ។ អង្គការ Pact បានដកការគាំទ្ររបស់ខ្លួនថ្វីត្បិតតែ CDFRY ក្រោយមកបាន ទទួលការគាំទ្រពី អង្គការមួយ ឬ ពីរ ដទៃទៀត ក៏ដោយ ជាទូទៅយើងឃើញថា CDFRY គ្មានសកម្មភាពកម្មវិធីណាមួយដែលជាក់ស្តែងបានត្រូវបញ្ចប់អោយសំរេចបាន ដល់គោលដៅឡើយ ។ នាឆ្នាំបន្តបន្ទាប់មកទៀត CDFRY បានត្រូវបើកសាខាការិយាល័យរបស់ខ្លួន នៅក្នុងខេត្តកំពង់ចាម ប៉ុន្តែ ក្នុងការតាមដានសួរជាបន្តបន្ទាប់នាខែមិថុនា ឆ្នាំ ២000 ជាមួយនឹង អង្គការ គណៈកម្មការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ស្តារកម្ពុជា និងអ្នកសំរបសំរួលបណ្តាញការងារ NGO ប្រចាំខេត្តកំពង់ចាម ដូចជា អង្គការ ADHOC និង ស្តារកម្ពុជា បានប្រាប់បញ្ចេញអោយដឹងថាគេមិនបានឃើញមានសកម្មភាពអ្វីមួយរបស់អង្គការ CDFRY ឡើយ ។ ភាពបរាជ័យរបស់អង្គការនេះ អាចជាលទ្ធផលមកពីកង្វះខាតតម្លាភាព និង ការតាំងចិត្តក្នុងនាមជាអ្នកដឹកនាំ អង្គការ ។

ការដួលរំលំអង្គការសហព័ន្ធពន្លឺខ្មែរ-ដែលជា**“ពន្លឺ”**យ៉ាងជាក់ច្បាស់មួយ សំរាប់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដែលមានសមាជិក របស់ខ្លួនជិត ១00 អង្គការ - វាគឺជាបញ្ហាស្មុគ្រស្មាញសាំញ៉ាំមួយ ក្នុងការវិភាគ

ហើយត្រូវបានគេលើកយកមកពិភាក្សាយ៉ាងច្រើន និង សរសេរនៅកន្លែងផ្សេងទៀត ។ អង្គការពន្លឺខ្មែរចាប់ផ្តើមដំណើរការចេញពីចលនាប្រជាជនមូលដ្ឋានដើម្បីជំរុញអោយមានសន្តិភាពមុនពេលបោះឆ្នោត ឆ្នាំ១៩៩៣ ហើយបានលើកទឹកចិត្តអោយ ប្រជាជនចូលរួមធ្វើការបោះឆ្នោត ។ នៅក្នុងពាក្យសាមញ្ញ យើងអាចនិយាយបានថា អង្គការពន្លឺខ្មែរ ប្រហែលជាព្យាយាមរហ័សពេកក្នុងការផ្លាស់ប្តូរយ៉ាងលំបាកពីចលនាប្រជាជនមូនដ្ឋានដើម្បីក្លាយទៅជាអង្គការផ្លូវការមួយ ។ ដោយហេតុថាវាគឺជាអង្គការសមាជិកភាពមួយ មានដំណើរការស្មុគស្មាញហើយបន្ថែមពីលើនោះទៀត មានគំនិតផ្សេងៗគ្នា ដូចជាថាតើតើអង្គការនេះគួរត្រូវគ្រប់គ្រងយ៉ាងដូចម្តេច ហើយនរណាគួរតែគ្រប់គ្រងអង្គការនេះ ។ វិបត្តិកើតមានឡើងនៅពេលដែលម្ចាស់មូលនិធិ (រួមបញ្ចូលទាំងអង្គការ Pact) ចាប់ផ្តើមផ្តល់មូលនិធិទៅដល់អង្គការ ហើយសមាជិកទាំងអស់របស់អង្គការ គ្មានមូលនិធិដោយផ្ទាល់ខ្លួនទេ ។ ការណ៏នេះបានបង្កើតស្ថានភាពអតុល្យភាព រវាងអង្គការ និង សមាជិកនានារបស់ខ្លួន ។ នៅខណៈពេលដែលវិបត្តិកើតឡើងពេលនោះអង្គការចាប់ផ្តើមចុះខ្សោយហើយបានធ្វើអោយអង្គការ នេះក្លាយជាគោលដៅចាប់អារម្មណ៏សំរាប់អំណាចដើម្បីបំរើផលប្រយោជន៏នយោបាយហើយធ្វើអោយអង្គការនេះឈានទៅរកទីបញ្ចប់ ។ នៅពេលដែលអង្គការពន្លឺខ្មែរបន្តថែរក្សាការិយាល័យហើយនិង មាននៅលើតែក្រដាស់ ការសំភាសន៏របស់យើងបានបង្ហើបអោយដឹងថាអង្គការនេះគ្មានសកម្មភាពទេ ហើយនៅសល់ តែអនុស្សាវរីយ៏យ៉ាងឈឺចាប់សំរាប់តួអង្គនានា ដែលបានចាប់អារម្មណ៏ ក្នុងការគាំទ្រអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅកម្ពុជា ។អាចនិយាយបានថាផលចុងក្រោយបំផុតរបស់អង្គការនេះបានបង្កើតអោយមានភាពមិនជឿទុកចិត្តរបស់អង្គការសមាជិកភាព ក្នុងស្រុកក្នុងចំណោម អង្គការមិនមែនរដ្ឋាភិបាល និង ការការពារពួកគេមិនអោយ មានការបង្ហាញសំខាន់ៗ នៅក្នុងថ្នាក់ជាតិ ។

អង្គការ BWAP បានចាប់ផ្តើមដំណើរការនាពាក់កណ្តាលឆ្នាំ ១៩៩៣ នៅពេលដែលអង្គការ Pact បានសំរេចផ្តល់មូលនិធិគាំទ្រដល់ក្រុមស្ត្រីដើម្បីចាប់ដំណើរការធ្វើអង្កេតមួយស្តីអំពី HIV/AIDSនៅក្នុងទីរួមខេត្តបាត់ដំបង ។ ចាប់តាំងពីពេលនោះមកអង្គការនេះត្រូវបានគេផ្តល់មូលនិធិដើម្បីផ្តល់ការអប់រំជំងឺអេដស៏ដល់ប្រជាជន ដប់ពាន់នាក់ ហើយ ជាសំខាន់គឺត្រូវផ្តោតយកចិត្តទុកដាក់ទៅលើក្រុមងាយទទួលរងគ្រោះដូចជាអ្នករកស៊ីផ្លូវភេទ និងមន្ត្រីយោធា ។ ថ្វីបើមាន ការផ្តល់ជំនួយបច្ចេកទេសយ៉ាងខ្លាំងក្លាពីអង្គការ Pact ហើយបន្ទាប់មកទៀត ពីអង្គការសម្ពន្ធ័ភាពអន្តរជាតិប្រយុទ្ធនឹងជំងឺអេដស៏ (International HIV/AIDS Alliance) (សព្វថ្ងៃនេះមានឈ្មោះថាអង្គការសម្ពន្ធ័ភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៏ KHANA)ប៉ុន្តែ BWAP

បានមានបញ្ហាជាបន្តបន្ទាប់ដូចជាវិបត្តិលើការគ្រប់គ្រងហើយវិបត្តិនេះចេញមកពីទំនាស់បុគ្គល ។ករណីអង្គការ BWAP គឺជាការបញ្ជាក់យ៉ាងច្បាស់លាស់ អំពីសារៈសំខាន់ នៃរចនាសម្ព័ន្ធគ្រប់គ្រង ដែលជាយន្តកម្មមួយ សំរាប់ដោះស្រាយទំនាស់ផ្ទៃក្នុង ។ ប៉ុន្តែជំនាញបច្ចេកទេស របស់ BWAPនៅក្នុងវិស័យអប់រំ HIV/AIDS កម្មវិធីទាក់ទងទៅនឹងHIV/AIDSសំរាប់កម្ពុជាបច្ចុប្បន្ន និង សមត្ថភាពបុគ្គលិកមានលទ្ធភាពបន្តទំនាក់ទំនង ជាមួយម្ចាស់មូលនិធិយ៉ាងល្អ សំរាប់ពេលអនាគតប្រសិនបើរចនាសម្ព័ន្ធគ្រប់គ្រងប្រាកដមួយ ត្រូវបានដាក់ អោយចំកន្លែងភ្លាមដូចដែលបានមានផែនការ ។ អង្គការ BWAPតំណាងអោយមេរៀនសំខាន់មួយសំរាប់ ភាពជាអ្នកដឹកនាំដែលយើងដឹងថាអង្គការនឹងមិន អាចដំណើរការបានឡើយ ប្រសិនបើ គ្មានរចនាសម្ព័ន្ធ គ្រប់គ្រង ។

## សេចក្តីសន្និដ្ឋាន

ដោយបានផ្តល់ចំនួនអង្គការNGOsដែលគាំទ្រដោយអង្គការ Pact និង ដោយហេតុថាអង្គការទាំងនោះទើប តែបង្កើតថ្មី ហើយម្យ៉ាងអង្គការជាច្រើនដែលលើកយកមកជាឧទាហរណ៍ ថាអង្គការ Pact ជាម្ចាស់មូលនិធិ ដំបូងដូចនេះបរាជ័យមានក៏វិតមួយទាប ដែលអាចលើកលែងបាន ។ ទោះបីជាយើងនឹងធ្វើការពិភាក្សាជាច់ ដោយឡែកខាងក្រោមស្តីអំពីនិរន្តភាពហិរញ្ញវត្ថុក៏ដោយ ប៉ុន្តែផ្តើមចេញពីជំហរអង្គការនោះអង្គការដែលបាន កើតឡើងជាច្រើនមានសមត្ថភាពបន្ត អនុវត្តសកម្មភាពអភិវឌ្ឍន៍ ធនធានមនុស្សរបស់ខ្លួនពុះពារ ដោះស្រាយ វិបត្តិនៃការគ្រប់គ្រង ហើយ ស្វែងរកម្ចាស់មូលនិធិសំរាប់គាំទ្រអង្គការរបស់ពួកគេ ។

## ៦. ការរកឃើញនានា

ការរកឃើញនានាដែលអធិប្បាយខាងក្រោមនេះបានមកដោយផ្អែកទៅលើការបញ្ជប់ប្រវត្តិរបស់អង្គការ
ចំនួន ៣២ ។

## ៦.១. រចនាសម្ព័ន្ធគ្រប់គ្រង

អង្គការចំនួន ៣២ ដែលបានបញ្ចប់ប្រវត្តិ (Profile) យើងបានកំណត់ រចនាសម្ព័ន្ធគ្រប់គ្រង៤ នៅពីខាងក្រៅ
អង្គការក្នុងចំណោមគំរូខាងក្រោម :

- ក្រុមប្រឹក្សាភិបាល
- គណៈទីប្រឹក្សា, គណៈកម្មាធិការ ទីប្រឹក្សា ឬ ទីប្រឹក្សាជាបុគល

- គណៈកម្មាធិការ នាំមុខ (ជ្រើសរើសសមាជិក ប៉ុន្តែពេលខ្លះបុគ្គលិកជ្រើសរើសពួកគេ)
- មហាសន្និបាតទូទៅ

យើងក៏បានកំណត់រកឃើញអង្គការដែលមានរចនាសម្ព័ន្ធគ្រប់គ្រងពីខាងក្នុងដែលបានជ្រើសរើសឡើងដោយបុគ្គលិកដែរ ។មានពាក្យផ្សេងៗដែលគេប្រើប្រាស់សំរាប់អធិប្បាយរចនាសម្ព័ន្ធទាំងនេះក៏ប៉ុន្តែនៅក្នុងរបាយការណ៍នេះ យើងនិយាយសំដៅជាទូទៅថា ជាគណៈកម្មាធិការគ្រប់គ្រង ។ អង្គការមួយចំនួនបានបញ្ជាក់ថាពួកគេគ្មានរចនាសម្ព័ន្ធគ្រប់គ្រងអ្វីទាំងអស់ ក្រៅពីគ្រប់គ្រងដោយនាយក ។

## ក្រុមប្រឹក្សាភិបាល

អង្គការ១២ ក្នុងចំណោម ៣២ (៣៨%) បានគូសបញ្ជាក់ថាអង្គការពួកគេមានក្រុមប្រឹក្សាភិបាល[៥] ។ ហើយក្នុងនោះដែរមានអង្គការ៥ (១៦%)ត្រូវបានគេរកឃើញថាសកម្ម អង្គការ១ សកម្ម ប៉ុន្តែមិនទៀងទាត់ អង្គការចំនួន៥មិនសកម្មហើយអង្គការ១ទៀតទើបតែបង្កើតឡើងដូចនេះវាឆាប់រហ័សពេកក្នុងការនិយាយប្រាប់ ។អ្នកឆ្លើយមួយចំនួនបានបញ្ជាក់ប្រាប់ថាពួកគេមានបទពិសោធន៍លំបាកក្នុងការរកមនុស្សដែលមានការស្ម័គ្រចិត្តធ្វើជាសមាជិកក្រុមប្រឹក្សាភិបាល ។

យ៉ាងហោចណាស់ក៏មានអង្គការចំនួន៣ដែរបានចង្អុលបញ្ជាក់ថាពួកគេបរាជ័យក្នុងការចាប់ផ្តើមធ្វើការជាមួយក្រុមប្រឹក្សាភិបាល ហើយនៅទីបញ្ចប់មិនអាចដោះស្រាយបាន ។

ចំនួនសមាជិកក្រុមប្រឹក្សាភិបាលមានពី៣ទៅ១០នាក់ហើយជាមធ្យមមានចំនួន៥នាក់ ។ពាក់កណ្តាលនៃចំនួនអង្គការដែលបានសំភាសន៏បានបញ្ជាក់ថាពួកគេមានជនបរទេសធ្វើជាក្រុមប្រឹក្សាភិបាលរបស់គេ (ហើយ NGOs មួយចំនួនព្យាយាមចាប់ផ្តើមដំណើរការក្រុមប្រឹក្សាភិបាល ដោយកំពុងស្វែងរក អ្នកស្ម័គ្រចិត្តដែល ជាជនបរទេស) ការបញ្ជាក់នេះប្រហែលមកពី ជនកម្ពុជាមានអារម្មណ៍ថា ពួកគេមានការជឿទុកចិត្តច្រើនប្រសិនបើមានវត្តមាន ជនបរទេស ដើម្បីត្រួតពិនិត្យ មើលអំពីតុល្យភាពអំណាចនៅក្នុងអង្គការ ។

សមាជិកក្រុមប្រឹក្សាភិបាលភាគច្រើនបំផុតមានមុខងារជានាយកឬបុគ្គលិកថ្នាក់ខ្ពស់នៅក្នុងអង្គការដទៃទៀតតែអង្គការមួយចំនួនទៀតមានសមាជិកមកពីផ្នែកឯកជន វិទ្យាស្ថានឧត្តមសិក្សាព្រះសង្ឃនិងជួនកាល ជាមន្ត្រីរាជការ (គួរឱ្យភ្ញាក់ផ្អើលបំផុតដែលពួកគេ មកពីក្រសួងការពារជាតិ) ។ គ្មានNGOផ្នែកអភិវឌ្ឍន៏ សហគមន៏

ជនបទណាមួយ មានសមាជិកក្រុមប្រឹក្សារបស់ខ្លួនជាអ្នកធ្វើការខាងក្រៅសហគមន៍ NGOsឡើយ (អាចជាអ្នកដឹកនាំ ឬជាសមាជិកជំនួញក្នុងមូលដ្ឋាន) ។

នៅពេលដែលយើងសួរអំពីតួនាទីរបស់ក្រុមប្រឹក្សាភិបាល នោះយើងទទួលបានចំលើយតប ដូចខាងក្រោម :

- ផ្តល់ជាប្រឹក្សា ឬគោលការណ៍ណែនាំ ( ៨ ចំលើយ )
- ពិនិត្យឡើងវិញនូវកម្មវិធីការធ្វើផែនការគោលនយោបាយថ្មីៗ និង យុទ្ធសាស្រ្តសំរាប់ ការបណ្តុះ បណ្តាល (7)
- ធ្វើជាបណ្តាញការងារទាក់ទងជាមួយអ្នកផ្តល់មូលនិធិ ត្រួតពិនិត្យ សំណើរ និងស្វែងរកមូលនិធិ (6)
- ជ្រើសរើសបុគ្គលិកថ្នាក់ខ្ពស់ នាយកនិងបុគ្គលិក (5)
- តាមដានត្រួតពិនិត្យលក្ខន្តិកៈ (4)
- ជំនួយបច្ចេកទេស

លើកលែងតែពីរឬបីក្រុមប្រឹក្សាភិបាល ដែលមានកិត្តិសព្ទល្បីសំរាប់ធ្វើជា រចនាសម្ព័ន្ធផ្លូវការ ប៉ុន្តែជាទូទៅចំណាប់អារម្មណ៍ដែលបានផ្តល់ក្នុងពេលធ្វើសំភាសន៍ គឺភាគច្រើនបំផុត នៃក្រុមប្រឹក្សាភិបាលបន្ត ធ្វើជាអ្នកប្រឹក្សាយោបល់ ជាជាងធ្វើជាអ្នក ដែលមានតួនាទីគ្រប់គ្រង (Governing Role) ហើយដែលNGOs ក្នុងស្រុកមានការវាងវៃក្នុងការបង្កើតឡើង ដើម្បីបង្កើនឱ្យមានភាពត្រឹមត្រូវតាមច្បាប់ នៅក្នុងក្រសែភ្នែករបស់អ្នកផ្តល់ជំនួយរបស់ពួកគេ ។

> *ជាស្ថាបនិកមួយរូប ខ្ញុំមិនចង់ក្លាយជានាយកប្រត្តិបត្តិរបស់អង្គការសប្បុរសទេ ។ ខ្ញុំបានសុបិន្តអំពីទស្សនៈរបស់ខ្ញុំសំរាប់អង្គការអស់រយៈពេលជាង១០ឆ្នាំ ។*

នៅក្នុងករណីដែលអ្នកផ្តល់ជំនួយមិនត្រូវការចាំបាច់ឬមិនទាន់លើកទឹកចិត្តឱ្យមានក្រុមប្រឹក្សាភិបាលនោះយើងមើលឃើញយ៉ាងច្បាស់ថាស្ថាបនិក/នាយកអង្គការភាគច្រើនបំផុតមិនជំរុញឱ្យមានការជ្រើសរើសរចនាសម្ព័ន្ធរបៀបនេះឡើយ ។ពួកគេមានអារម្មណ៍ថាពួកគេមានហេតុផលត្រឹមត្រូវ តាមផ្លូវច្បាប់ក្នុងករណីមិនចង់ឱ្យមានក្រុមប្រឹក្សាភិបាល ហើយក្នុងនាមជាស្ថាបនិក អង្គការពួកគេនៅតែអាចអភិវឌ្ឍន៏ និង អនុវត្តន៏បានតាមទស្សនៈរបស់អង្គការ ហើយពួកគេនឹងមិនបានជឿជាក់ភាគច្រើនបំផុតទៅលើសមាជិកក្រុម ប្រឹក្សាភិបាល ដើម្បីប្រគល់អំណាចគ្រប់គ្រង (Governing Power) ពេញលេញដល់ពួកគេឡើយ ។

## គណៈកម្មាធិការទីប្រឹក្សា ឬទីប្រឹក្សាជាបុគ្គល

អង្គការ ៩ ដទៃទៀត (២៨%) បាននិយាយថា ពួកគេមានគណៈកម្មាធិការទីប្រឹក្សា ដែលបានជួយពួកគេយ៉ាងទៀងទាត់ដើម្បីផ្តល់ជាប្រឹក្សាយោបល់ជាទូទៅនិងលើបច្ចេកទេសព្រមទាំងបានជួយពួកគេក្នុងការធ្វើផែនការជាយុទ្ធសាស្ត្រនិងបណ្តុះបណ្តាលការងារ ។ ចំនួនសមាជិកទីប្រឹក្សានៅក្នុងគណៈកម្មាធិកានីមួយៗមានពី១ ដល់ ៥ នាក់ ។ដោយមានតួនាទីជាក្រុមប្រឹក្សាភិបាលនោះគណៈកម្មាធិការទីប្រឹក្សាត្រូវបានកើតឡើងដោយសារការរួមបញ្ចូលគ្នារវាងជនកម្ពុជា និងជនបរទេស ហើយអ្នកទាំងនោះភាគច្រើនបំផុតបំរើការនៅក្នុង NGOs ។ គណៈកម្មាធិការទីប្រឹក្សារបស់អង្គការ CVCD គឺកើតមក ពីការរួមបញ្ចូលសមាជិកនានារបស់អង្គការ ។ អង្គការចំរើនស្ត្រីមានរចនាសម្ព័ន្ធទាំងពីរគឺគណៈក្រុមប្រឹក្សា និងគណៈកម្មាធិការទីប្រឹក្សា ។

ភាគច្រើនបំផុត គណៈកម្មាធិការទីប្រឹក្សានេះកើតមានឡើងដោយសារការសំរបសំរួលរវាងគំនិតដែលថា គណៈក្រុមប្រឹក្សាត្រូវការអោយមានជាចាំបាច់ប៉ុន្តែជាក់ស្តែងភាពជាអ្នកដឹកនាំមិនទាន់រៀបចំស្រួលបួលសំរាប់គណៈក្រុមប្រឹក្សានៅឡើយទេ ។ នៅក្នុងរយៈពេលនេះគណៈកម្មាធិការ ទីប្រឹក្សាអាចមានប្រយោជន៏បំផុតសំរាប់ជួយក្នុងការបង្កើតទិសដៅថ្មីនិងបង្កើតជាសម្ព័ន្ធភាពថ្មីសំរាប់អង្គការ ។ឧទាហរណ៏មានគណៈកម្មាធិការទីប្រឹក្សាមួយរបស់ Outreach ដែលបានណែនាំអំពីគំនិតនៃសកម្មភាពតាមដានត្រួតពិនិត្យដល់ការអប់រំសិទ្ធិមនុស្សនៅតាមខេត្តនានា និង សហប្រតិបត្តការជាមួយ អង្គការ CIHR ។

## គណៈកម្មាធិការនាំមុខ

អង្គការនិស្សិត សម្ព័ន្ធភាពNGOsនិងអង្គការសមាជិកភាពនានាមានគណៈកម្មាធិការនាំមុខ ។នៅក្នុងប្រភេទនេះយើងឃើញមាន សមាគមនិស្សិតបញ្ញវន្តខ្មែរ (KSIA) ដែលមានគណៈកម្មាធិការទីប្រឹក្សា កើតមកពីសមាជិកស្ថាបនិក និងសមាជិកធម្មតា ហើយក៏ដូចគ្នាទៅនឹងអង្គការKottarak(ជាសម្ព័ន្ធភាពមួយ នៃអង្គការ៤នៅខេត្តបាត់ដំបង) និងអង្គការ MEDICAM ដែលជាអង្គការសមាជិកភាពរបស់ NGOs ធ្វើការលើផ្នែកសុខភាព ។

## គណៈកម្មាធិការគ្រប់គ្រង

តាមរយៈការអង្កេត អង្គការចំនួន៤ (១២.៥%) បានបញ្ជាក់ថាពួកគេគ្មានរចនាសម្ព័ន្ធគ្រប់គ្រង មកពីខាង

ក្រៅទេ ប៉ុន្តែអង្គការ ពួកគេពិតជាមានគណៈកម្មាធិការគ្រប់គ្រង ដែលជួបគ្នាដោះស្រាយ ទំនាស់ផ្ទៃក្នុង និងបង្កើតគោលការណ៍អង្គការ ។ ការជួបគ្នានេះអាចធ្វើឡើងដោយផ្អែកទៅលើមូលដ្ឋាន ទៀងទាត់ ឬ ឆ្លើយតបទៅនឹងបញ្ហាជាក់លាក់នានា ។ ជាការចាប់អារម្មណ៏កត់សំគាល់ផងដែរថាអង្គការ៣ ក្នុងចំណោម អង្គការ៤មានគណៈកម្មាធិការគ្រប់គ្រង (BFD, LICADHO and Samakee) ជាទូទៅត្រូវបានគេចាត់ ទុកថា ជាអង្គការ NGOsខ្លាំងមួយ ។ ក្នុងករណីអង្គការ BFD គណៈកម្មាធិការគ្រប់គ្រងដោះស្រាយរាល់ការ សំរេចចិត្តលើការគ្រប់គ្រងក៏រិតខ្ពស់នៅពេលដែលស្ថាបនិក/នាយកអវត្តមានក្នុងរយៈពេលពីរឆ្នាំដើម្បីបន្តការ សិក្សានៅឯបរទេស ។អង្គការទី ៤ដែលមានគណៈកម្មាធិការទីប្រឹក្សាគឺ CVCDក៏មានគណៈកម្មាធិការនាំមុខ ដែរ ដែលមានសមាជិក ៧ រូប ។

## រចនាសម្ព័ន្ធចំរុះ

អង្គការADHOCមានរចនាសម្ព័ន្ធគ្រប់គ្រងខុសពីធម្មតាមួយក្នុងគោលបំណងបញ្ចូលគ្នានូវភាពត្រឹមត្រូវតាម ផ្លូវច្បាប់ របស់អង្គការជាមួយនឹង វិធីសាស្ត្រ ជាប្រពៃណីរបស់ប្រជាជនកម្ពុជា ចំពោះសមាគម ។ លទ្ធផល នេះគឺជារចនាសម្ព័ន្ធគ្រប់គ្រងចំរុះដែលកើតចេញមកពីការសន្និបាតទូទៅ ក្នុងការជ្រើសរើសប្រធាន អគ្គលេខា ធិការនិងមន្ត្រីផ្សេងៗទៀត (បុគ្គលិក) ព្រមទាំងគណៈទីប្រឹក្សាដែលជាអ្នក ផ្តល់ភាពត្រឹមត្រូវតាមផ្លូវច្បាប់ នៅក្នុង ក្រសែភ្នែករបស់ NGO និងសហគមន៏អ្នកផ្តល់មូលនិធិនានា ។

គណៈទីប្រឹក្សាមានសមាជិក៥រូបក្នុងនោះរួមមាន៣រូបជាជនបរទេសដែលមានមុខនាទីទទួលខុសត្រូវក្នុងការ ផ្តល់គំនិតនិងគោលការណ៏ណែនាំ ។សន្និបាតទូទៅធ្វើឡើងរៀងរាល់៣ឆ្នាំម្តងនិងជាស្ថាប័ន្តបង្កើតគោលការណ៏ ខ្ពស់បំផុតរបស់អង្គការ ។ បុគ្គលិកជាង ១00នាក់របស់អង្គការ ADHOC និងសកម្មជននានា ចូលរួមក្នុង កិច្ចប្រជុំនេះ ។ មហាសន្និបាតបានបោះឆ្នោតជ្រើសរើសប្រធាននិង មន្ត្រីនានាដើម្បីត្រួតពិនិត្យរាល់ការងារគ្រប់ គ្រងទាំងមូល ការប្រតិបត្តិកម្មវិធី និង កិច្ចការរដ្ឋបាល ។ ប្រមាណជា ៧0% នៃអ្នកដែល ចូលរួមនៅក្នុង មហាសន្និបាត ជាបុគ្គលិក ឬ ជាសកម្មជនស្ម័គ្រចិត្ត ។

## រចនាសម្ព័ន្ធគ្រប់គ្រងមិនផ្លូវការ

មាន ៦ NGOs (19 %)នៅក្នុងការធ្វើអង្កេតបានបញ្ជាក់ថាពួកគេគ្មានរចនាសម្ព័ន្ធគ្រប់គ្រងបែបផ្លូវការទេ ។ ឧទាហរណ៏ដូចជាអង្គការBWAPដែលបានធ្វើការអធិប្បាយនៅក្នុងផ្នែកទី៥ខាងលើ ។វាបង្ហាញភាពមិនដូចគ្នា

ទៃដែលអង្គការ ៣ ផ្សេងទៀត (KRDA, Saboras និង MODE) បានទទួលជំនួយមូលនិធិភាគច្រើនពី ICCO ។ អ្នកស្រាវជ្រាវយើងបានសួរអង្គការ ICCO អំពីគោលការណ៍ ដែលទាក់ទងទៅនឹង រចនាសម្ព័ន្ធ គ្រប់គ្រង។ ការឆ្លើយតបមកវិញគឺថានៅក្នុងដំណាក់កាលនៃការអភិវឌ្ឍន៍របស់ NGOs កម្ពុជា ICCO មានការបារម្ភច្រើនទៅនឹងសមត្ថភាព របស់អង្គការនៅក្នុងការបញ្ចូលកម្មវិធីទៅនឹងក្រុមគោលដៅ របស់ខ្លួននិងជាមួយសមត្ថភាពបុគ្គលិកដើម្បីធ្វើការងាររួមគ្នា ។

## សន្និដ្ឋាន

ជាទូទៅគំនិត នៃរចនាសម្ព័ន្ធគ្រប់គ្រងស្ថិត នៅក្នុងភាពមិនទាន់យល់ច្បាស់លាស់ និង រារែកនៅឡើយចំពោះ NGO ក្នុងស្រុកភាគច្រើន ។ សំពាធក្នុងការបង្កើតឡើងនូវក្រុមប្រឹក្សាភិបាលច្រើន កើត ចេញមកពីអ្នកផ្តល់មូលនិធិ (albeit subtly) ជាជាងអ្នកដឹកនាំ NGOs យល់ដោយខ្លួនឯង អំពីផលប្រយោជន៍ដល់អង្គការរបស់ខ្លួន ។ហេតុផលមួយក្នុងចំណោមហេតុផលនានារបស់ ICCO បានចង្អុល បញ្ជាក់ថា អាចមកពី NGO កម្ពុជាភាគច្រើនគ្មានឱកាសក្នុងការ សង្កេតមើល គណៈក្រុមប្រឹក្សា របស់ NGO អន្តរជាតិដែលមានដំណើរការពីព្រោះ គណៈកម្មាធិការទាំងនោះមិនបានស្ថិតនៅក្នុងប្រទេសកម្ពុជា។ កត្តារួមចំណែកដទៃទៀតបណ្តាលមកពីកង្វះភាពជឿជាក់ ទៅលើបុគ្គលដែលខ្លួនអញ្ជើញមក ធ្វើជាគណៈក្រុមប្រឹក្សាថា នឹងអាចរួមចំណែកដោយមិនលំអៀង។ ហេតុផលចុងក្រោយ បានគូសបញ្ជាក់ ការពិត ថា ថ្នាក់ដឹកនាំ NGOs មិនបានរៀន (មិនត្រូវបានគេបង្រៀន) ថាសមាជិកគណៈក្រុមប្រឹក្សាត្រូវតែទទួលការណែនាំ ហើយការអប់រំទៅដល់គណៈក្រុមប្រឹក្សាគឺជាផ្នែកមួយនៃដំណើរការងារ នេះ។

អភិបាលកិច្ចបង្ហាញពីបញ្ហាពិសេសរបស់ស្ថានិក/នាយកដែលជាអ្នកមានអំណាចពេញលេញនៅក្នុងអង្គការរបស់គេ ហើយមិនអាច សំរុះសំរួលរវាងតួនាទីរបស់ខ្លួន ជាមួយ នឹង តួនាទី របស់គណៈក្រុមប្រឹក្សា ។ ក្នុងចំណោមទាំងអស់នោះយើងអាចបញ្ចូលអង្គការ KRDA, សប្បុរស និង BFD ។ចំពោះនាយកអង្គការដែលខ្លួនមិនមែនជាស្ថាបនិក (ដូចជា អង្គការ USG) គឺងាយស្រួលក្នុងការទទួលយកគំនិត ស្តីពីគណៈក្រុមប្រឹក្សា ។ ទោះបីជាយ៉ាងណាក៏ដោយ បណ្តាស្ថាបនិក/នាយកអង្គការដែលយើង បាននិយាយជាមួយបាននឹងកំពុងគ្រប់គ្រងអង្គការរបស់ពួកគេ ស្ទើតែមួយទស្សវត្សន៍ហើយ ឥឡូវនេះពួកគេចាប់ផ្តើមមានអារម្មណ៍ថាពួកគេបានទទួលជោគជ័យនូវអ្វីដែលពួកគេមានផែនការធ្វើហើយរៀបចំខ្លួនជាស្រេចដើម្បីខិតខំប្រឹងប្រែង(Challenges)នៅខាងក្រៅអង្គការរបស់ពួគេ ។ ដូច្នេះជាមួយនឹងរយៈពេល ៥ឆ្នាំខាងមុខទៀត

អ្នកដឹកនាំអង្គការទាំងនេះ នឹងចាប់ផ្តើមគិតពិចារណាដោយយក ចិត្តទុកទៅលើការ បង្កើតគណៈក្រុមប្រឹក្សា ដើម្បីធ្វើអោយងាយស្រួល ក្នុងដំណើរការរីកចំរើនអង្គការរបស់ខ្លួន ។

## ៦.២. ការតស៊ូមតិ និងបណ្តាញការងារ

### ការតស៊ូមតិ

ដោយសង្ខេបប្រវត្តិយ៉ាងខ្លី អង្គការកម្ពុជានានាបានបង្កើតការអភិវឌ្ឍន៍ដ៏ គួរឱ្យចាប់អារម្មណ៍មួយទៅលើ ផ្នែកការតស៊ូមតិ ។ ជាមួយនឹងរបាយការណ៍ ឬ ពតិមានរបស់អង្គការ Pact នៅកំរិតថ្នាក់ជាតិ NGO កម្ពុជា កំពុងធ្វើការតស៊ូមតិយ៉ាងសកម្ម សំរាប់សិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិពលកម្ម សិទ្ធិជនរស់នៅក្នុងសំណង់ អនាធិបតេយ្យ សិទ្ធិដីធ្លី គោលនយោបាយសុខភាព ហើយបន្ថែមពីលើនេះទៀត គឺសកម្មភាព របស់ ព្រះសង្ឃ នៅក្នុងការអភិវឌ្ឍន៍សហគមន៍។ អង្គការចំនួន ៣០ដែលយើងបានធ្វើការសំភាសន៍ ធ្វើការតស៊ូមតិ ឬ ចូលរួម នៅក្នុង បណ្តាញការងារការតស៊ូមតិនានា ។

អង្គការស្តារកម្ពុជាធ្វើការនៅក្នុងបណ្តាញការងារតស៊ូមតិដោយខ្លួនឯងនិងការសហការជាមួយនឹងអង្គការជាង ៣០ទៀតនៅក្នុងប្រទេស ។អង្គការស្តារកម្ពុជាបានបង្កើតបណ្តាញការងារដោយផ្តោតទៅលើបញ្ហាជាក់លាក់ នានានៅតាមបណ្តារខេត្តជាច្រើន ហើយនាពេលថ្មីៗនេះ បានចាប់ផ្តើម ធ្វើការទៅលើសិទ្ធិពលកម្ម ។ សកម្មភាពតស៊ូមតិដែលមានការចាប់អារម្មណ៍ស្មើៗគ្នានោះត្រូវបានធ្វើឡើងក្នុងចំនួនតិចតួចបន្ថែមទៀតនៅ ក្នុងកំរិតថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន ។ នៅក្នុងខេត្តបាត់ដំបងអង្គការជីវិតថ្មីបាន ប្រាប់អោយដឹង ក្នុងឆ្នាំកន្លងមកថារបាយការណ៍ប្រចាំឆ្នាំថ្នាក់ខេត្តមួយបានចោទប្រកាន់ថាNGO មានស្មុកអាវុធ ។ជាការឆ្លើ យតបអង្គការជីវិតថ្មីបានតាមដានរឿងរ៉ាវនោះ តាមរយៈនាយកដ្ឋានរបស់រដ្ឋាភិបាលជាច្រើន ដើម្បីអះអាង ថាគ្មាន ភស្តុតាងណាមួយគាំទ្រទៅដល់ការចោទប្រកាន់នោះឡើយ ។ បន្ទាប់មកអង្គការជីវិតថ្មីបានចែកចាយ របាយ ការណ៍ចំលងទៅដល់អង្គការ ចំនួន ៧០ នៅក្នុងខេត្តបាត់ដំបង ដោយមានភ្ជាប់ជាមួយនឹងលិខិតតវ៉ា ។ សកម្មភាពនេះបានធ្វើអោយអាជ្ញាធរថ្នាក់ខេត្តមានប្រតិកម្មតបនិងនិយាយថាគេនឹងធ្វើការពិនិត្យមើលទៅលី បញ្ហានេះ ។

នៅក្នុងកំរិតថ្នាក់មូលដ្ឋាន NGOsខ្លះបានបញ្ជាក់ថាពួកគេបានបង្កើតទំនាក់ទំនងល្អជាមួយនឹងអាជ្ញាធរដែនដី

ជាកិច្ចការ មួយដែលមិនមែនជាការងាយស្រួលឡើយចំពោះ NGOsក្នុងស្រុកភាគច្រើនត្រូវ បានសង្ស័យថាមានការពាក់ព័ន្ធ នឹងការងារនយោបាយ ។ ដោយបង្ហាញខ្លួនឯងតាមរយៈការងាររបស់គេ នោះ NGOs បានបង្កើនការជឿជាក់ ដល់មន្ត្រីថ្នាក់មូលដ្ឋាន ហើយមានលទ្ធភាពក្នុងការ ធ្វើអន្តរាគមន៍ យ៉ាងជោគជ័យនៅក្នុងជម្លោះនានានៅតាមមូលដ្ឋាន ដែលរួមមានបញ្ហាការយកដីសហគមន៍ មកធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួននិងការ ចាប់យកឧបករណ៏កសិកម្ម (ម៉ាស៊ីនបូមទឹក) ដែលធ្វើឡើងដោយមន្ត្រីយោធានានា ។
ជាធម្មតាអង្គការផ្នែកសិទ្ធិមនុស្សបានពង្រឹងសមត្ថភាពយ៉ាងខ្លាំងសំរាប់ការតស៊ូមតិហើយដោះស្រាយជាមួយបញ្ហានានាយ៉ាងលំបាកបំផុត ។ ភាពរឹងមាំរបស់ពួកគេកើតចេញពីប្រវត្តិដ៏យូររបស់ពួកគេ( អង្គការផ្នែកសិទ្ធិមនុស្សភាគច្រើន ត្រូវបានបង្កើត ឡើងក្នុងឆ្នាំ ១៩៩១ មុនការទទួលស្គាល់ជាផ្លូវការ) និងដោយហេតុថា បុគ្គលិក និងសកម្មជនស្ម័គ្រចិត្ត របស់ពួកគេតែងតែជាជនរងគ្រោះបណ្ដាលមកពីការរំលោភលើសិទ្ធិមនុស្ស ។

## បណ្ដាញការងារ

សេចក្ដីត្រូវការសំរាប់ពង្រឹងសាមគ្គីភាពនោះអង្គការផ្នែកសិទ្ធិមនុស្សតែងតែនាំមុខគេនៅក្នុងការបង្កើតបណ្ដាញការងារដើម្បីដោះស្រាយ ចំពោះអង្គការនីមួយៗ ដែលមិនអាចធ្វើបានតែម្នាក់ឯង ។ អង្គការទាំងនេះរួមមាន គណៈកម្មាធិការសកម្មភាពសិទ្ធមនុស្ស (Human Rights Action Committee), COMFREL, COFFEL និងអង្គការដទៃទៀត ។

ចាប់តាំងពីមានការដួលរលំអង្គការពន្លឺខ្មែរមកនោះអង្គការផ្នែកអភិវឌ្ឍន៏សហគមន៏ភាគច្រើនមានបណ្ដាញការងារនៅតាមខេត្តនានា និងមានបណ្ដាញការងារអង្គការ១ឬ ២ ទៀតនៅភ្នំពេញ ។ខណៈពេលដែលអង្គការ Pact បានគាំទ្រដ៏សំខាន់ ទៅលើអង្គការ ផ្នែកអភិវឌ្ឍន៏សហគមន៏ និងអង្គការផ្នែកគាំទ្រ នោះអង្គការក្នុងស្រុកនានាផ្សេងៗ បានចូលរួមនៅក្នុងបណ្ដាញការងារដោយប្រមូលផ្ដុំបញ្ហាជាឧទាហរណ៏តាមរយៈ វេទិកាអង្គការមិនមែនរដ្ឋាភិបាល (NGO FORUM ) ។ ជាប្រការគួរអោយចាប់អារម្មណ៏ គឺមានអង្គការចំនួន ១៥បានបញ្ជាក់ថាពួកគេបានចូលរួម នៅក្នុងបណ្ដាញ ការងារអន្តរជាតិ ដែលផ្ដោតទៅលើ បញ្ហាចាប់ពីសិទ្ធិស្ត្រីរហូតដល់សិទ្ធិទីលំនៅ (Housing Rights) ។

## សន្និដ្ឋាន

នៅក្នុងខណៈដែលអង្គការដែលផ្ដោតការយកចិត្តទុកដាក់ទៅលើសិទ្ធិមនុស្ស សិទ្ធិស្ត្រីនិងបញ្ហាផ្សេងៗទៀតកំពុងចូលរួមនៅក្នុងការតស៊ូមតិនោះអង្គការផ្នែកអភិវឌ្ឍន៏សហគមន៏មានសកម្មភាពតិចតួចទៅលើវិស័យ

ខាងលើនេះ ។ ការខិតខំប្រឹងប្រែងនៅក្នុងការពង្រឹងសមត្ថភាពរហូត មកដល់ពេលនេះ បានផ្តោតទៅលើ ការពង្រឹង អង្គការ និងកម្មវិធី ហើយក៏យកចិត្តទុកដាក់ ដើម្បីលើកទឹកចិត្តអង្គការផ្នែកអភិវឌ្ឍន៍សហគមន៍ ដើម្បីអភិវឌ្ឍន៍ ជំនាញតស៊ូមតិ (ដូចជានៅក្នុងសិក្ខាសាលា ស្តីអំពីការតស៊ូមតិ ដែលរៀបចំ ឡើងដោយ អង្គការ Pact កាលពីខែកក្កដាឆ្នាំ ១៩៩៩) ដែលផ្នែកនេះនៅមានកំរិតនៅឡើយ ក្នុងតាមដាន ត្រួតពិនិត្យ ។

## ៦.៣. មូលដ្ឋានមូលនិធិ

ដើម្បីប៉ាន់ប្រមាណមូលដ្ឋានមូលនិធិរបស់ដៃគូរអង្គការ Pact អ្នកស្រាវជ្រាវរៀបចំបង្កើតក្រាហ្វិចអំពី មូលនិធិ ជំនួយនិងចំណូលផ្សេងៗទៀត នៅក្នុងអង្គការរបស់ពួកគេ ។ ក្រាហ្វិចពេញលេញមួយ អាចមើលនៅក្នុង ឧបសម្ព័ន្ធ B ។ នៅក្នុងផ្នែកនេះ យើង លើកយកឧទាហរណ៏ដោយពន្យល់លើក្រាហ្វិចតែ ពី ឬ បី ប៉ុណ្ណោះ ។

### មូលនិធិជំនួយ

### អង្គការផ្នែកតស៊ូមតិ

ក្នុងចំណោម ២៩ អង្គការដែលយើងបានប្រមូលទិន្នន័យនៅលើផ្នែកហិរញ្ញវត្ថុ គឺមានតែអង្គការចំនួន ៣ ប៉ុណ្ណោះដែលអាចត្រូវបាននិយាយថាមានស្ថេរភាពមូលដ្ឋានមូលនិធិ ។យើងចង់និយាយថាអង្គការទាំងនេះបាន ទទួលជំនួយមូលនិធិពី អង្គការនានាយ៉ាងច្រើន នៅក្នុងឆ្នាំកន្លងមកហើយការគាំទ្រនេះត្រូវបានរំពឹងថានឹងបន្ត ទៅមុខទៀត ។អង្គការដែលភាគច្រើនទទួលជោគ ជ័យគឺអង្គការផ្នែកតស៊ូមតិ ដូចជាក្រុមអង្គការសិទ្ធិមនុស្ស និងក្រុម អង្គការ តស៊ូមតិ ។ ឧទាហរណ៏ យើងបានជ្រើសរីសយកមកពន្យល់តាមក្រាហ្វិចដូចជា ADHOC (អង្គការសិទ្ធិ មនុស្ស) និង USG(សិទ្ធិរស់នៅក្នុងសំណង់អាណាធិបតេយ្យ) ដែលបង្ហាញដូចខាងក្រោមនេះ :



ដូចដែលបានឃើញតាមក្រាហ្វិចទាំងពីរដែលបានបង្ហាញថាអង្គការទាំងនេះ បានទទួលមូលនិធិជាទៀងទាត់ពីម្ចាស់មូលនិធិ ពី ៨ ទៅ ១០ ក្នុង មួយឆ្នាំៗ ។ ក្នុងខណៈនេះអង្គការ ADHOC ហាក់ដូចជាទទួលជំនួយបច្ចុប្បន្នតិចជាងឆ្នាំ១៩៩៧និង១៩៩៨ ហើយ ជំនួយដែលឡើងខ្ពស់នៅឆ្នាំទាំងពីរនេះគឺអាចបានមកពីលទ្ធផលនៃមូលនិធិសំរាប់ការត្រួតពិនិត្យការបោះឆ្នោត ។ និន្នាការជាទូទៅចំពោះមូលនិធិឃើញថាមានការកើនឡើងហើយការផ្តល់មូលនិធិសរុបមានច្រើន (លើស ៦00,000 ដុល្លា) ។ ចំពោះអង្គការ USG វិញនិន្នាការអាចឃើញ ច្បាស់ថាមានការកើនឡើងទោះជាមូលនិធិទាំងអស់ទាបជាង១៤0,000ដុល្លា ក៏ដោយ ។




អង្គការដទៃទៀតបានទទួលការគាំទ្រទៀងទាត់រាល់ឆ្នាំក្នុងចំនួនកំណត់មួយពីម្ចាស់មូលនិធិ ។ អង្គការទាំងនេះរួមមាន ក្រុមអង្គការផ្នែកតស៊ូមតិ ដូចជាសមាគមឆ្នបកម្ពុជាហើយដែលបាន បង្ហាញតាមក្រាហ្វិច ដូចខាងក្រោមនេះ:




តាមក្រាហ្វិច បានបង្ហាញឱ្យឃើញថា Pact ជាម្ចាស់មូលនិធិដំបូង ហើយ បន្ទាប់មកមានភ្នាក់ងារផ្តល់មូលនិធិដទៃទៀតដែលគាំទ្រដល់ឆ្នប ឬ ផែនការគ្រួសារ ដែលឥឡូវនេះបានផ្តល់ការគាំទ្រជាទៀងទាត់ដល់ CMA ហើយ មានកំរិតប្រហាក់ប្រហែលគ្នា នឹង Pact ដែរ ។

## **អភិវឌ្ឍន៍សហគមន៍**

យើងសង្កេតឃើញថាមូលនិធិមានការប្រែប្រួលខ្លាំងនៅក្នុងការផ្តល់មូលនិធិទៅអោយអង្គការផ្នែកអភិវឌ្ឍន៍សហគន៏ក្នុងចំណោមអង្គការនិង នៅក្នុងអង្គការនានាបណ្តាឆ្នាំបន្តបន្ទាប់ ។ អង្គការBFDបានទទួលមូលនិធិដែល មានស្ថេរភាពចាប់តាំងពី អង្គការនេះបានបង្កើតមក ទោះបីជាកំរិតមូលនិធិថយចុះក៏ដោយ (សូមមើលក្រាហ្វិចBFDខាងក្រោមនេះ នៅក្នុងការបង្កើនប្រាក់ចំណូល) ។ អង្គការសាមគ្គីក៏មានស្ថេរភាពផ្នែកមូលដ្ឋានមូលនិធិ និងម្ចាស់មូលនិធិជាច្រើនផងដែរ ប៉ុន្តែកំរិតនៃការផ្តល់មូលនិធិទូទៅ ក៏មានការថយចុះផងដែរ ។



អង្គការអភិវឌ្ឍន៍សហគមន៍ដទៃទៀតមានទំរង់មូលនិធិមិនទៀងទាត់ជាច្រើនព្រមជាមួយគ្នានោះក៏រឹតនៃការផ្តល់មូលនិធិមានការថយចុះ ប៉ុន្តែ នៅក្នុងករណីទាំងនេះជាការជាក់ស្តែងដែលភ្នាក់ងារម្ចាស់ជំនួយបានជ្រើសយកការមិនបន្តគាំទ្រដល់អង្គការទាំងនេះដោយគ្មានកំណត់ ។ វាបានបង្ហាញថាអង្គការទាំងនេះមានការឈ្លាសវៃក្នុងការរកម្ចាស់មូលនិធិថ្មីមក ជំនួសជារៀងរាល់ឆ្នាំ ។ អង្គការដទៃខ្លះទៀតមានការ ស្រុតចុះថវិការ ដូចជាអង្គការរចនា ដែលពិពណ៌នាតាមក្រាហ្វិចខាងក្រោមនេះ




## អង្គការសមាជិកភាព

ជាអង្គការសមាជិកភាពមួយ អង្គការMEDICAM បានពឹងផ្អែកជាសំខាន់ទៅលើម្ចាស់មូលនិធិ នានាដែលជាប្រភពនៃមូលនិធិរបស់ខ្លួន ។ ប្រភេទនៃការគាំទ្រនេះមានភាពមិនទៀងទាត់ ហើយ មានភាពប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ។



## ការបង្កើនប្រាក់ចំណូល

## អង្គការផ្អែកតស៊ូមតិ

ជាទូទៅអង្គការផ្អែកតស៊ូមតិមិនបានស្វែងរកមូលនិធិចេញពីប្រភពក្រៅពីម្ចាស់មូលនិធិឡើយ ។នៅរាល់ដើមឆ្នាំអង្គការ ADHOC បានរៃអង្គាសពីសកម្មជនឬអ្នកស្ម័គ្រចិត្តសិទ្ធិមនុស្សប៉ុន្តែទោះបីជាចំនួនទឹកប្រាក់បន្តិចបន្តួចនេះក៏ដោយក៏ត្រូវបានគេបង្ហាញអោយឃើញថាចំនួនទឹកប្រាក់មានកំរិតខ្ពស់សំរាប់ការបរិច្ចាករបស់អ្នកស្ម័គ្រចិត្ត ដូច្នេះការអនុវត្តន៍ត្រូវបានបញ្ឈប់ ។ ចំណែកឯអង្គការ USG វិញម្តងម្កាលបានធ្វើការស្វែងរកមូលនិធិតូចៗ សំរាប់ករណីសង្គ្រោះបន្ទាន់ ប៉ុន្តែវាគ្មានសកម្មភាពបន្តសំរាប់ការផ្តល់មូលនិធិដទៃទៀតឡើយ ។

## អង្គការផ្អែកអភិវឌ្ឍន៍សហគមន៍

ការកើនឡើងនៃ ចំនួនអង្គការ ផ្អែកអភិវឌ្ឍន៍សហគមន៍ បានចាប់ផ្តើមរកប្រាក់ចំណូលចេញ ពីប្រភពដទៃទៀត ។ ភាគច្រើនបំផុតរកបានប្រាក់ចំណូលដោយសារ ការប្រាក់នៃសកម្មភាពឥណទានហើយប្រធានបទនេះបានក្លាយជាចំនុចរួមសំរាប់ពិភាក្សាពិចារណាក្នុងចំណោមសហគមន៍NGOs ដោយយល់ថាការកើនឡើងនេះអង្គការមាន បំណងបង្កើនការទទួលខុសត្រូវ លើចំណាយប្រតិបត្តិរបស់ខ្លួន ដោយយកការប្រាក់ពីអ្នកក្រ ។ ដូចដែលយើងបានឃើញក្រាហ្វិចរបស់អង្គការសាមគ្គីខាងលើដែលបង្ហាញថា ៣០% នៃប្រាក់ចំណូលរបស់ខ្លួនឥឡូវនេះគឺរកបានមកពីការប្រាក់ឥណទាន ។

ម្យ៉ាងទៀតចំនួនអង្គការមួយ ចំនួនតូចកំពុងតែ ពង្រឹងជំនាញផ្នែកការស្វែងរកមូលនិធិរបស់ពួកគេ ហើយចាប់ផ្តើមរកមូលនិធិកាន់តែច្រើនឡើងៗចេញពីការស្វែងរកមូលនិធិពីសាធារណៈ ។អង្គការKRDA បានរកចំណូលពីគ្រប់សេវាកម្មទាំងអស់ ចាប់ពីការថតចំលង រហូតដល់លក់ស្រោមអនាម័យ ។ រយៈពេល ២ឆ្នាំកន្លងទៅនេះអង្គការ KRDA រកចំណូលបាន ៤,៥០០ ដុល្លាក្នុងមួយឆ្នាំដោយខ្លួនឯងផ្ទាល់សំរាប ចំណាយប្រតិបត្តិ ។ ឧទាហរណ៍មួយទៀតគឺអង្គការBFD បានរៃអង្គាសវិភាគទាននៅក្នុងប្រទេសហើយកំពុងចាប់ផ្តើមរកមូលនិធិច្រើនទៀតតាមរយៈBFD អន្តរជាតិ ដែលមានមូលដ្ឋានស្ថិតនៅ Lowell, Massachussetts ដែលជាកន្លែងធំទី២របស់សហគមន៍ខ្មែរ-អាមេរិកាំងនៅសហរដ្ឋអាមេរិក ។ តាមរយៈអង្គការ BFD អន្តរជាតិឥឡូវនេះមាន លទ្ធភាពទាក់ទងតាម Internet ដោយផ្តល់មូលនិធិសិក្សាសំរាប់កុមារនៅក្នុងខេត្តបាត់ដំបង ។ នៅពេលប្រាក់ចំណូលដែលរកបានមានចំនួនតិចតួច បើប្រៀបធៀបទៅនឹងការផ្តល់មូលនិធិ របស់ម្ចាស់ជំនួយនេះគឺជាការងាយស្រួលមួយពីព្រោះBFD មានមូលនិធិសរុបទាំងអស់ក្នុងមួយឆ្នាំលើសពី ២០០,០០០ដុល្លា ។




## អង្គការនិស្សិត/អង្គការអ្នកស្ម័គ្រចិត្ត

CVCD, KSIA និង KSA ជាអង្គការសមាជិកទាំងបី ដែលក្រុមគោលដៅរបស់ខ្លួន គឺ និស្សិត និងយុវជន ។ សមាជិកទាំងឡាយដែលចូលរួមនៅក្នុងសមាគមមិន បានបង់ប្រាក់ទេហើយ អាចចូលរៀនកុំព្យូទ័រ និង ភាសាអង់គ្លេសក្នុងអត្រាតំលៃមួយទាបជាងសេវាឯកជនសមាជិកនានាតំរូវឱ្យមានការចូលរួមនៅក្នុងសកម្មភាពសមាគមន៏ដូចជា ការដាំដើមឈើ និង ទិវារបោសសំអាត ។ នៅចុង ឆ្នាំ១៩៩0ក្រុមទាំងនេះមានលទ្ធភាពរកចំណូលបានពីថ្នាក់រៀនរបស់ខ្លួន ចំនួនសមាគមនិស្សិតបានផ្តល់សេវាកម្មដូចគ្នានេះ មានការកើតឡើងហើយការរកចំណូលដោយខ្លួនឯងបានថយចុះក្នុងចំណោមអង្គការនានាដែលបានបង្កើតឡើង ។ នៅក្នុងករណីអង្គការCVCDពិបាកក្នុងការរកជំនួយថវិកាពីម្ចាស់មូលនិធិហើយអង្គការKSAពឹងផ្អែកទាំងស្រុងទៅលើមូលនិធិពីអង្គការតែមួយ ដែលមានឈ្មោះថា ទេយ្យទានជាតិ ដើម្បី លទ្ធិប្រជាធិបតេយ្យ National Endowment for Democracy :






## សន្និដ្ឋាន

ជាទូទៅអង្គការផ្នែកតស៊ូមតិមានការផ្តល់មូលនិធិ(ម្ចាស់មូលនិធិ)ស្ថេរភាពជាងបណ្តាអង្គការផ្នែកអភិវឌ្ឍន៏សហគមន៏អង្គការសមាជិកភាពឬសមាគមនិស្សិត ។នៅខណៈពេលដែលអង្គការផ្នែកអភិវឌ្ឍន៏សហគមន៏បានបង្កីនប្រាក់ចំណូលយ៉ាងច្រើនពីកម្មវិធីឥណទាននោះអង្គការភាគច្រើនមានការលំបាកក្នុងការរក្សាកំរិតនៃការផ្តល់មូលនិធិរបស់ពួកគេ ។មានតែអង្គការធំៗមួយចំនួនប៉ុណ្ណោះដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលការបរិច្ចាក ពីសាធារណះនៅក្នុងប្រទេស និង ក្រៅប្រទេស ។ ដោយមិនមានបង្ហាញនៅលើ ក្រាហ្វិចបណ្តាអង្គការផ្នែកបណ្តុះបណ្តាលនានាកំពុង តែប្រកួតប្រជែង ដើម្បី រស់ដោយថ្លៃឈ្នួលដែលបាន មកពីការបណ្តុះបណ្តាល តែមួយមុខគត់ហើយបង្ហាញអោយឃើញពីការត្រឡប់ទៅរកម្ចាស់មូលនិធិ ។

នៅកំឡុងពេលសំភាសន៏ស្ទើរតែគ្រប់អង្គការទាំងអស់មានការបារម្ភណ៏អំពីអនាគតមូលនិធិរបស់ខ្លួន ។ដោយមានករណីលើកលែងខ្លះនោះ ការតាំងចិត្តរបស់ម្ចាស់មូលនិធិធ្វើឡើងដោយឈរលើគោលការណ៏មួយឆ្នាំម្តងៗដូច្នេះសូម្បីតែអង្គការADHOCជានិច្ចកាលតែងតែបារម្ភណ៏អំពីថាតើមូលនិធិនឹងបានមកពីកន្លែងណាសំរាប់សកម្មភាពនៅឆ្នាំក្រោយ ។

## ៦.៤. គណនេយ្យភាព និង តម្លាភាព

### ការជំរះបញ្ជី

អង្គការទាំង៣២មានទំរង់ពេញលេញហើយអង្គការ១៣(៤១%) មានការជំរះបញ្ជីពីខាងក្រៅដោយក្រុមហ៊ុននានាដូចជា ErnstYoung , Price Waterhonse Optima (Philippines)ឬក្រុមហ៊ុនជំរះបញ្ជីមកពីម៉ាឡេស៊ី ។ អង្គការ៦ទៀត(១៩%) បានបញ្ជាក់ថាម្ចាស់មូលនិធិរបស់ពួកគេតែងតែមកជំរះបញ្ជីយ៉ាងទៀងទាត់ ។

អង្គការចំនួន១០ទៀត(៣១%)មិនបានជំរះបញ្ជីទេ ហើយយើងខ្វះពតិមានទាក់ទង នឹង អង្គការដែលនៅសល់ ៤ ទៀត ។

វត្តមាននៃការជំរះបញ្ជីពីខាងក្រៅធ្វើឡើងដោយផ្ទាល់ ទៅតាមគោលការណ៏របស់ភ្នាក់ងារមូលនិធិ ។ ភ្នាក់ងារ ផ្តល់មូលនិធិនៅក្នុង ប្រទេសដែលមាន បុគ្គលិកហិរញ្ញវត្ថុ របស់ខ្លួនគ្រប់គ្រាន់ តែងតែធ្វើការត្រួតពិនិត្យហិរញ្ញវត្ថុរបស់ដៃគូខ្លួន។ ម្ចាស់មូលនិធិដែលគ្មានវត្តមាននៅក្នុងប្រទេស តែងតែត្រូវការការជំរះបញ្ជីពីក្រុមហ៊ុនឯកជន ហើយបញ្ចូលតំលៃនៃការជំរះបញ្ជីនោះទៅក្នុងថវិកា ។ ឧទាហរណ៏អង្គការ ៤ ក្នុងចំណោម ៦ អង្គការ ដែលជាដៃគូរបស់អង្គការ Pact ហើយសព្វថ្ងៃនេះត្រូវបានគាំទ្រដោយ ICCO គឺមានការជំរះបញ្ជីពីខាងក្រៅយ៉ាងទៀងទាត់ ។

បណ្តាអង្គការនានាដែលទទួលការជំរះបញ្ជីជាទៀងទាត់ មានអារម្មណ៏ល្អជាមួយនឹងដំណើរការនេះដែលពីមុនគេមានការព្រួយបារម្ភណ៏ចំពោះពួកគេ ។អ្នកឆ្លើយម្នាក់បានឆ្លើយថាៈ
*“ មុនពេលធ្វើការជំរះបញ្ជីជាលើកទីមួយបុគ្គលិករបស់ខ្ញុំទាំងអស់មានការព្រួយបារម្ភណ៏ ។ឥឡូវនេះយើងរីករាយដើម្បីអោយមានការជំរះបញ្ជីពីខាងក្រៅពីព្រោះថាបន្ទាប់ពីនោះមកយើងអាចដឹងអំពីភាពខ្លាំងនិងភាពខ្សោយរបស់យើងហើយយើងអាចកែលំអរវាបាន ។យើងទទួលយកការជំរះបញ្ជីពីខាងក្រៅពីព្រោះវាមានសារៈសំខាន់ និងយើងត្រូវការចំលើយតប” ។*

*អង្គការ WFP អនុវត្តតម្លាភាពនៅក្នុងអង្គការ និងជានិច្ចកាលចែករំលែកបទពិសោធន៍ជាមួយបុគ្គលិកទាំងអស់ ។ នៅក្នុងទស្សនៈរបស់ពួកគេ បុគ្គលិកដែលមានការតាំងចិត្តតិចតួចហើយបានដឹងអំពីអស្ថេរភាពនៃហិរញ្ញវត្ថុរបស់អង្គការនឹងស្វែងរកការងារផ្សេងទៀត ហើយចាកចោលបុគ្គលិកដែលមានការតាំងចិត្ត ។*

កំឡុងពេលធ្វើការអង្កេតអ្នកស្រាវជ្រាវបានធ្វើការវាយតំលៃទៅលើរបាយការណ៏ជំរះបញ្ជីនានា។ សូម្បីតែការជំរះបញ្ជីត្រូវបានគេនិយាយថាមានតំលៃថ្លៃ ប៉ុន្តែរបាយការណ៏ទាំងនេះ យើងពិនិត្យឃើញថាវាសង្ខេបខ្លីៗនិងមិនបានរួមបញ្ចូលអំពីរបាយការណ៏ការប្រាក់ចំណូល ។យ៉ាងហោចណាស់ ក៏មានមួយករណីដែរ ដែលក្រុមហ៊ុនជំរះបញ្ជីមិនបានទៅដល់ការិយាល័យអង្គការឡើយ ។ ដូច្នេះការជំរះបញ្ជីពីខាងក្រៅ គឺជាគំនិតល្អមួយ ប៉ុន្តែប្រសិនបើពួកគេដឹកនាំតាមលក្ខខ័ណ្ឌការងារ ដែលមានការមិនច្បាស់លាស់ នោះបណ្តារម្ចាស់មូលនិធិ និងភ្នាក់ងារផ្តល់ មូលនិធិនឹងបញ្ឈប់ការចង់ដឹងអំពីការជំរះបញ្ជីរបស់អង្គការដែលមានកំរិតស្តង់ដាខ្ពស់លើការអនុវត្តផ្នែក

ហិរញ្ញវត្ថុ ហើយ ការជំរះបញ្ជីនឹងបាត់បង់ភាពជឿទុកចិត្តរបស់ពួកគេ ។

ដូចដែលបានអធិប្បាយពីមុនមកហើយថាភ្នាក់ងារជួយគាំទ្រនៅក្នុងប្រទេសគឺផ្តល់ការគាំទ្រទៅលើការពង្រឹងសមត្ថភាពតែងតែសកម្មក្នុងការធ្វើការជំរះបញ្ជីដល់ដៃគូររបស់ខ្លួន ។នៅពេលដែលពួកគេដឹងថាដៃគូររបស់ខ្លួនធ្វើបានល្អហើយនោះ ការជំរះបញ្ជី គឺគ្រាន់តែផ្តល់នូវរូបភាពដ៏សុក្រិត្យ នៃស្ថានភាពហិរញ្ញវត្ថុរបស់អង្គការ និង ទំរង់ការនានាប៉ុណ្ណោះ ។

## គណនេយ្យភាព

អង្គការចំនួន ២៥ ក្នុងចំណោម ៣២អង្គការ (៧៨%) បានរៀបចំរបាយការណ៏ប្រចាំឆ្នាំរបស់ខ្លួន ។ ភាគច្រើនបំផុតនៃរបាយការណ៏នេះបានបញ្ចូលរបាយការណ៏ប្រាក់ចំណូលហើយចំពោះNGOsដែលរក ចំណូលពីប្រភពផ្សេងៗទៀតក្រៅពីមូលនិធិ ក៏ពួកគេតែងតែបញ្ចូលពតិមាននេះ នៅក្នុងរបាយ ការណ៏ផងដែរ ។ NGOsភាគច្រើនបានរៀបចំរបាយការណ៏ប្រចាំឆ្នាំរបស់ខ្លួនជាភាសាអង់គ្លេសនិងចែក ចាយដល់ម្ចាស់ មូលនិធិរបស់ពួកគេតែប៉ុណ្ណោះ ។ អង្គការខ្លះទៀតដូចជា អង្គការផ្នែកសិទ្ធិមនុស្ស និងក្រុម ផ្នែកតស៊ូមតិត្រូវបានពន្យល់ថា ការងាររបស់ពួកគេបង្កើតភាពតានតឹងជាមួយនឹង អាជ្ញាធររដ្ឋាភិបាលដូចនេះការរៀបចំ របាយការណ៏របស់ខ្លួន ធ្វើឡើងសំរាប់តែ អង្គការនៅខាងក្រៅ តែប៉ុណ្ណោះ ។ មានតែ NGO មួយចំនួនតូចតែប៉ុណ្ណោះដែលសរសេររបាយការណ៏ប្រចាំឆ្នាំ ជាភាសាខ្មែរ ដែលធ្វើងាយស្រួល យល់ចំពោះ NGOs កម្ពុជា និងជាពិសេសអ្នកដឹកនាំសហគមន៏មូលដ្ឋាន។ ក្នុងចំណោម NGO ដែលធ្វើ ការអង្កេតមានតែ NGO ចំនួនមួយប៉ុណ្ណោះដែលសរសេររបាយការណ៏ ពីរភាសា ចែកចាយដល់ សមាជិក សហគមន៏-ដោយធ្វើការគុសបញ្ជាក់ អំពីការណែនាំរបស់ម្ចាស់មូលនិធិទៅលើគណនេយ្យភាព ។

## សន្និដ្ឋាន

គ្រប់អង្គការដែលបានធ្វើសំភាសន៏មានការទទួលយកការជំរះបញ្ជីពីខាងក្រៅដោយបានទទួលការកើនឡើងនូវភាពជឿទុកចិត្តនិងរៀនសូត្រពីចំណុចខ្លាំងនិង ចំណុចខ្សោយរបស់ពួកគេ ។ មូលហេតុចំបងដែលNGOs នានាមិនត្រូវការ ការជំរះបញ្ជីដោយសារពួកគេមិនមាន មូលនិធិ នៅក្នុងគំរោងថវិកា សំរាប់សកម្មភាព នេះ ហើយម្ចាស់មូលនិធិរបស់ពួកគេ មិនបានផ្តល់ថវិកាចំណាយ ទៅលើ សេវាកម្ម នេះឡើយ ។

អង្គការដែលយើងបានសំភាសន៏ពេញចិត្តទៅនឹងការជំរះបញ្ជីទៅលើអង្គការជាជាងការជំរះបញ្ជីលើគំរោង។ បុគ្គលិកអង្គការ បានចំណាយពេលយ៉ាងច្រើនជាមួយនឹង អ្នកជំរះបញ្ជីមកពីម្ចាស់មូលនិធិនានាក្នុងរយៈផ្សេងៗ

គ្នានៃឆ្នាំ ។ រហូតដល់ NGOs បានបង្កើន ភាពជឿជាក់គ្រប់គ្រាន់ដើម្បីដាក់ការគាបសង្កត់លើ ម្ចាស់មូលនិធិរបស់ខ្លួនដើម្បីធ្វើការជំរះបញ្ជីក្នុងអង្គការទាំងមូលតែម្តងប៉ុន្តែវាអាស្រ័យទៅលើភ្នាក់ងារម្ចាស់ មូលនិធិដែលធ្វើការសហការ ជាមួយនឹងម្ចាស់មូលនិធិដទៃទៀតហើយ បង្កើតជាប្រព័ន្ធហិរញ្ញវត្ថុមួយហើយទំរង់ការ ជំរះបញ្ជីមានការទទួលយកបានពីគ្រប់ភាគីទាំងអស់ ។ ជាគោលការណ៍ អង្គការ Pact គាំទ្រការជំរះបញ្ជីសំរាប់អង្គការទាំងមូល ប៉ុន្តែធ្វើឡើង នៅ ពេលណាដែលត្រូវការប៉ុណ្ណោះ ។

ចំពោះជាទស្សនះរបស់អង្គការទៅលើគណនេយ្យភាព នៅតែមានការផ្តោតទៅលើការ បំពេញចិត្តដល់ម្ចាស់មូលនិធិនិងមានការខិតខំប្រឹងប្រែងតិចតួច (ឬ ប្រហែលជាការលើកទឹកចិត្ត) ដើម្បីដឹកនាំអង្គការអោយចាប់ ផ្តើមធ្វើការប្រាស្រ័យទាក់ទងអំពីសកម្មភាពរបស់ ពួកគេទៅនឹងតំបន់គោលដៅរបស់ពួកគេ ។ ប្រភេទនៃការប្រឹងប្រែងនេះ មានសារៈសំខាន់ពីព្រោះវានឹងជួយជូនពត៌មាន ដល់សហគមន៍ស្តីអំពី សកម្មភាពនានារបស់ NGOs ហើយជួយពួកគេក្នុងការបង្កើនភាពជឿទុកចិត្តព្រមទាំងសង្ឃឹមថានឹងជួយលើកទឹកចិត្តក្នុងការរួម វិភាគទាន សំរាប់ ពេល អនាគត ។

## ៦.៥. ស្ថេរភាពនៃការគ្រប់គ្រង

ដើម្បីប៉ាន់ប្រមាណស្ថេរភាព នៃការគ្រប់គ្រង យើងត្រួតពិនិត្យទៅលើការ ផ្លាស់ប្តូរបុគ្គលិក និងវិបត្តិនៃការគ្រប់គ្រងហើយធ្វើការប្រៀបធៀបលទ្ធផល របស់យើងទៅនឹងរបៀបគ្រប់គ្រងរបស់អង្គការ ។ ក្នុងចំណោមអង្គការ៣២ យើងបានរកឃើញដូចខាងក្រោម :

- ២២ អង្គការដឹកនាំដោយស្ថានិកអង្គការ
- ៧ អង្គការ ដឹកនាំដោយបុគ្គលដែលគេបានតែងតាំង
- ៣ អង្គការដឹកនាំដោយស្ថាបនិក២ នាក់ (Co-founder) ដែលពួកគេជាផ្នែកមួយនៃក្រុមដែលមានឋានៈស្មើគ្នា

នៅក្នុងការវិភាគអំពីការផ្លាស់ប្តូរ បុគ្គលិកយើងបានចាត់ថ្នាក់អង្គការដោយអត្រាផ្លាស់ប្តូរទាប, មធ្យម, ខ្ពស់ ។ អត្រាផ្លាស់ប្តូរខ្ពស់បានបង្ហាញថា អង្គការដែលមាន បទពិសោធន៍យ៉ាងហោចណាស់មួយឆ្នាំអត្រា នៃការផ្លាស់ប្តូរបុគ្គលិក ប្រហែល ២០% ឬលើសពីនេះ ។ ដើម្បីវិភាគ អំពីបញ្ហានេះ យើងបានពិចារ

> *LICADHO គឺជាអង្គការមួយរឹងមាំដែលមានបញ្ហាទំនាស់ផ្ទៃក្នុងតិចតួច ។*
>
> *បញ្ហានៅ អតីតកាលបានកើតឡើង នៅពេលបុគ្គលិកប្រៀបធៀបប្រាក់បៀវត្សរបស់ពួកគេនិង ផលប្រយោជន៍ផ្សេងៗជាមួយ បុគ្គលិកដែលធ្វើការនៅអង្គការដទៃទៀត ។*

ណាថាភាគរយមិនទាក់ទង សំរាប់អង្គការតូចៗ ដែលមានការផ្លាស់ប្តូរបុគ្គលិកតែម្នាក់ ក្នុងមួយឆ្នាំដោយគិតថាមានអត្រាផ្លាស់ប្តូរខ្ពស់នោះទេ។ ប្រើប្រាស់វិធីសាស្ត្របែបនេះយើងបានរកឃើញថាអង្គការ២០មិនមានការផ្លាស់ប្តូរបុគ្គលិកខ្ពស់ទេ, អង្គការ ៧ មានការផ្លាស់ប្តូរមធ្យម (ប្រហែល 10%) នៅក្នុងឆ្នាំខ្លះ ហើយ ៤ អង្គការទៀតមានការផ្លាស់ប្តូរខ្ពស់ក្នុងរយៈពេលមួយឆ្នាំឬលើសពីនេះ។

> *" កំហុសរបស់ខ្ញុំគឺមិនបានត្រួតពិនិត្យគណនេយ្យករបស់ខ្ញុំពីព្រោះខ្ញុំបានជឿទុកចិត្តគាត់ "*

ទាក់ទងទៅនឹងទំនាស់ យើងបានរកឃើញថា អង្គការ១០ មានបទពិសោធន៍ ពីបញ្ហាលើផ្នែកគ្រប់គ្រង កាលពីអតីតកាល ជួនកាលនាំទៅដល់ ការបំបែកអង្គការ។ មានតែអង្គការមួយគត់ដែលមានវិបត្តិនៅពេលថ្មីៗនេះ។ អង្គការ ២១ ផ្សេងទៀតជាអង្គការដែលមានស្ថេរភាព។ វាគ្មានអ្វីគួរអោយ ភ្ញាក់ផ្អើលទេដែលលទ្ធផលបង្ហាញថា អង្គការ ៨ ក្នុងចំណោម ១០មានទំនាស់លើការគ្រប់គ្រងមានអត្រាផ្លាស់ប្តូរបុគ្គលិកខ្ពស់។ យើងក៏បានរកឃើញដែរ ថាអង្គការ ១១ ដែលមានការលំបាកផ្នែកគ្រប់គ្រងនៅ អតីតកាលបានកំពុងបន្ត មានការលំបាកផ្នែកគ្រប់គ្រងនេះ មកដល់ពេលបច្ចុប្បន្ន។ មានអង្គការនិស្សិត ៣ និងអង្គការ ៨ ទៀតបានដឹកនាំដោយស្ថាបនិកឥលូវនេះឬត្រូវបានដឹកនាំដោយស្ថាបនិកកាលពីពេលមានវិបត្តិ (ប៉ុន្តែឥលូវនេះរចនាសម្ពន្ធ័គ្រប់គ្រង របស់ពួកគេបានផ្លាស់ប្តូរ ហើយស្ថាបនិក លែងជាផ្នែកមួយសំរាប់ អង្គការនោះបន្តទៀតទេ)

## សន្និដ្ឋាន

ពីលទ្ធផលនេះ យើងសន្និដ្ឋានថាទំនាស់នៃការគ្រប់គ្រង កើតឡើងនៅក្នុងអង្គការដែល ដឹកនាំដោយស្ថាបនិករបស់ពួកគេជាជាងអង្គការដែលនាយកអង្គការត្រូវបានគេជ្រើសតាំង។ គួរកត់សំគាល់ថា ទំនាស់និងការផ្លាស់ប្តូរបុគ្គលិកមានកំរិតអប្បបរិមា នៅពេលណាស្ថាបនិក/នាយក មានការលើកទឹកចិត្តដល់បុគ្គលិក ។ ប៉ុន្តែសំនួរសួរថាតើការផ្លាស់ប្តូរ ជាយថាហេតុចំពោះ នាយកដែលមិនមែនជាស្ថាបនិកនឹងបន្តនៅក្នុង អង្គការទាំងនោះយ៉ាងដូចម្តេច?

## ៦.៦. ទិសដៅកម្មវិធី

អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាអាចចែកចេញជា ៤ ប្រភេទធំៗ :

- អង្គការផ្នែកអភិវឌ្ឍន៍សហគមន៍

- អង្គការផ្អែកតស៊ូមតិ
- អង្គការផ្អែកគាំទ្រនិងការបណ្តុះបណ្តាល
- អង្គការសមាជិកភាព (រួមទាំងសមាគមនិស្សិត)

អង្គការផ្អែកអភិវឌ្ឍន៏សហគមន៏ជាច្រើនចាប់ផ្តើមកម្មវិធីរបស់ពួកគេជាមួយនឹង សកម្មភាពសន្សំនិងឥណទាន និងបន្ថែមសកម្មភាព ផ្សេងៗ ទៀតដូចជា កសិកម្ម ការអប់រំសុខភាព អក្ខរកម្ម និង ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច។ ជាទូទៅកម្មវិធីភាគច្រើន បានរៀបចំដើម្បីតំរូវទៅតាមសេចក្តី ត្រូវការជាមូលដ្ឋានរបស់អ្នកទទួលផលហើយអ្នកទទួលផលភាគច្រើនមានតំរូវការជាមូលដ្ឋានដូចៗគ្នា ។ ផ្អែកតាមការសំភាសន៏ NGO មិនបានផ្លាស់ប្តូរកម្មវិធី របស់ពួកគេក្នុងក៏រិតធំធេងទេ នៅក្នុងអតីតកាលថ្មីៗនេះ ហើយមានតែ ២ឬ៣ ករណីប៉ុណ្ណោះដែល NGO អាចពន្យល់អំពី មូលហេតុ ដែលពួកគេ បានជ្រើសរើស ការផ្លាស់ប្តូរ វិធីសាស្ត្រ (Approach) របស់ពួកគេ។

មាន២ករណីដែលយើងបានរកឃើញថាអង្គការផ្អែកអភិវឌ្ឍន៏សហគមន៏បានបរាជ័យនៅពេលចាប់ផ្តើមហើយជាលទ្ធផលបានផ្លាស់ប្តូរទាំងស្រុង នូវកម្មវិធី វិធីសាស្ត្រនិងតំបន់គោលដៅ របស់ពួកគេ។ ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើន ដែលបានដកស្រង់ សំរាប់ការបរាជ័យនៃការចាប់ផ្តើមនេះ គឺជាការជ្រើសរើសជាដំបូងនៅ តំបន់គោលដៅមិនបានល្អ។ មានមួយករណី ភូមិគោលដៅជាច្រើន ត្រូវបានលិចលង់នៅរដូវវស្សាហើយមិនសង្ឃឹម ក្នុងការធ្វើអោយស្ថានភាពកាន់តែ ប្រសើរឡើងវិញទេ។ នៅក្នុងករណីទាំងពីរនេះ NGO មិនមានទីតាំងនៅក្នុងតំបន់គោលដៅ របស់ពួកគេទៀតទេ ហើយបញ្ហាបានកើតឡើង ដោយសារកង្វះខាតខាងការត្រួតពិនិត្យ។

នៅក្នុងករណីខ្លះទិសដៅកម្មវិធីត្រូវបានកំណត់ ដោយក្រុមម្ចាស់មូលនិធិ ដែលបញ្ចូលដោយផ្ទាល់ទៅនិងភាពដែលអាចរកបាននូវមូលនិធិដែលដៃគូ អាចអនុវត្តបាន។ មានមួយឬពីរករណីអង្គការបាន បង្ហាញថាទិសដៅកម្មវិធីត្រូវបាន កំណត់ដោយផ្អែក ទៅលើ ធនធានដែលទទួលបាន ពីទីប្រឹក្សាបរទេស។ ឧទាហរណ៏ មួយនៃគោលការណ៏ណែនាំ ពីខាងក្រៅចំពោះអង្គការ មួយអនុវត្តកម្មវិធី HIV/AIDS និងឥណទាន ដែលសកម្មភាពដោយឡែករបស់ HIV/AIDS ត្រូវបានគេអនុវត្តនៅក្រៅតំបន់គោលដៅដែលបានកំណត់។ ក្រុមខ្លះចង់បំបាត់សកម្មភាពឥណទាន របស់ពួកគេ ។ ដូចជាករណីអង្គការ ADHOC និង CREDO ខណ:ពេលដែល

អង្គការដទៃទៀតដូចជា Samakee មិនគិតថាសកម្មភាពនេះ ជាផលប្រយោជន៍ សំរាប់សកម្មភាពនៃការអភិវឌ្ឍន៏ទេ។

ម្យ៉ាងវិញទៀត អង្គការផ្នែក តស៊ូមតិ កំពុងចាប់ផ្តើម សកម្មភាពផ្សេងៗ និងចំគោលដៅ តួយ៉ាងដូចជា មជ្ឈមណ្ឌលស្តារលទ្ធភាព របស់អង្គការ ADHOC សំរាប់ជនរងគ្រោះដោយទារុណកម្ម និង គំរោងទើបចាប់ផ្តើម របស់អង្គការស្តារកម្ពុជាអំពីការផ្សព្វផ្សាយពត៌មានទៅលើដំណើរការច្បាប់។

តាំងពីពេលចាប់កំណើត អង្គការផ្នែកបណ្តុះបណ្តាលនិងអង្គការផ្នែកគាំទ្របានរកឃើញថាពួកគេស្ថិតនៅក្នុងតួនាទីមួយដែលពួកគេត្រូវតែធ្វើអោយប្រសើរឡើងនិងពិនិត្យសារឡើងវិញអោយបាន ទៀងទាត់ទៅលើសកម្មភាពរបស់ពួកគេ ដើម្បីតំរូវទៅនឹង ការផ្លាស់ប្តូរ និងសេចក្តីត្រូវការនៃ អតិថិជន របស់ពួកគេ ។ ជាឧទាហរណ៍ អង្គការវឌ្ឍនៈបានកំណត់លក្ខណៈនេះថាជាមូលហេតុនៃការថយចុះ ដល់ការចុះឈ្មោះ សំរាប់វគ្គបណ្តុះបណ្តាលអំពីមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៏សហគមន៏។

ដូចដែលបានបង្ហាញរួចមកហើយនៅក្នុងរបាយការណ៍ គំនិតដើម របស់សមាគមនិស្សិតគឺ ជួយគាំទ្រនិងលើកកំពស់សកម្មភាពអភិវឌ្ឍន៏ក្នុងចំណោមយុវជនកម្ពុជា ដោយផ្តល់អោយពួកគេនូវលទ្ធភាពអាចរកបានបាននៅថ្នាក់រៀនដែលមានតំលៃថោក ។ ប៉ុន្តែ ការប្រលងប្រជែងកើនឡើង សំរាប់ថ្នាក់រៀននិងសមត្ថភាព ក្នុងការធានា តំលៃនៃសកម្មភាពអភិវឌ្ឍន៏ធ្វើអោយ សមាគមនិស្សិតស្ថិតក្នុងភាពប្រឈមមុខទៅនឹង សកម្មភាពអភិវឌ្ឍន៏របស់ពួកគេហើយប្តូរទៅជាសាលារៀនឯកជនវិញ។

ករណីដែលប្លែកពីគេមួយហើយគួរអោយចាប់អារម្មណ៏ គឺអង្គការ KSIA ។ នៅឆ្នាំ ១៩៩៦ ការគ្រប់គ្រងមិនបានល្អបានបង្ខំអោយសមាគមនិស្សិតនេះបញ្ឈប់ប្រត្តិបិត្តការមួយរយៈពេលខ្លី ។ ការបោះឆ្នោតថ្មីដោយសមាជិក ភាពបានធ្វើអោយការដឹកភាពផ្លាស់ប្តូរ និងការគ្រប់គ្រងមានភាពប្រសើរឡើង។ អង្គការនេះ គឺជាអង្គការតែមួយគត់ដែលមានសមាជិកភាពជា និស្សិតហើយប្រលងចេញពី មហាវិទ្យាល័យទស្សនៈវិជ្ជា និង

អក្សរសាស្រ្តនៃសកលវិទ្យាល័យភ្នំពេញ ។ ឥលូវនិស្សិតទាំងនេះ ក្លាយជាគ្រូបង្រៀនហើយបច្ចុប្បន្ន បង្កើតឡើងវិញនូវ KSIA ជាពិសេសនៅតាមខេត្តនានា។

## សន្និដ្ឋាន

អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្នមិនមែនជា ក្រុមតែមួយនោះទេ (Homogenous Groups)។ វាមានលក្ខណៈ ច្បាស់លាស់ហើយមានប្រភេទផ្សេងៗ ហើយប្រភេទនីមួយៗ កំពុងអភិវឌ្ឍន៍ទៅមុខ។ អង្គការផ្នែកតស៊ូមតិបានបង្ហាញនូវភាពចាស់ទុំបំផុតនិងដែលមានសមត្ថភាពបំផុតក្នុងការអភិវឌ្ឍន៍កម្មវិធីតែមួយនេះ ។អង្គការផ្នែកគាំទ្រក៏បង្ហាញនូវភាពរឹងមាំដែរថ្វីបើពួកគេជានិច្ចកាលធ្វើការដើម្បីធ្វើអោយប្រសើរឡើងនូវគុណភាពសេវាកម្មរបស់គេ និងបន្តពឹងផ្អែកយ៉ាងខ្លាំងទៅលើម្ចាស់មូលនិធិ ។ អង្គការផ្នែកអភិវឌ្ឍន៍សហគមន៍មានជំនាញកើនឡើង សំរាប់អនុវត្តកម្មវិធីប៉ុន្តែមានគំនិតច្នៃប្រឌិតតិចលើការ រៀបចំកម្មវិធីជាជាងអង្គការផ្នែកតស៊ូមតិ។ អនាគតរបស់អង្គការនិស្សិតនៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ។

## ៦.៧. និរន្តភាពរបស់កម្មវិធី

ការយល់ជាទូទៅនៃ និរន្តភាពរបស់កម្មវិធីគឺ នៅមានកំរិតហើយជាញឹកញយបានកំណត់ជាមួយនិងនិរន្តភាពផ្នែកហិរញ្ញវត្ថុ។ នៅពេលយើងសួរ NGOs តើពួកគេកំពុង ធ្វើអ្វីដើម្បីបង្កើនជីវភាពរស់នៅនៃ និរន្តភាពកម្មវិធី ការឆ្លើយតបជារួម ភាគច្រើនបំផុត (ជាពិសេសក្នុងចំណោម អង្គការផ្នែកតស៊ូមតិ) ដែលពួកគេបានផ្តោតការយកចិត្តទុកដាក់ទៅលើសមត្ថភាព បុគ្គលិកនិងការអនុវត្តអោយ មានតម្លាភាពនៅក្នុង អង្គការ។ ប៉ុន្តែ អង្គការជាច្រើន កំពុងបារម្ភអំពីនិរន្តភាព របស់កម្មវិធី។

អង្គការសិទ្ធិមនុស្សមានឱកាសល្អ សំរាប់និរន្តភាពកម្មវិធី ពីព្រោះសកម្មភាពភាគច្រើន របស់ពួកគេពឹងផ្អែកលើសកម្មជនអ្នកស្ម័គ្រចិត្ត។ សកម្មភាពទាំងនេះ គឺភាគច្រើនសំរាប់ ជនរងគ្រោះផ្នែក ការរំលោភសិទ្ធមនុស្ស ហើយដោយសារហេតុផលនេះ ធ្វើអោយមានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីលើកកំពស់ការការពារសិទ្ធិមនុស្ស និងនិតិវិធី នៃច្បាប់។ មិនដូចគ្នា ទៅនឹងអ្នកស្ម័គ្រចិត្តផ្នែកអភិវឌ្ឍន៍សហគមន៍ទេ សកម្មជនផ្នែកសិទ្ធិមនុស្សមានសាមគ្គីភាពគ្នា ហើយ មិនទាមទារផលប្រយោជន៍ផ្សេងៗទៀត សំរាប់ការខិតខំប្រឹងប្រែង របស់ពួកគេទេ។

អង្គការផ្នែកអភិវឌ្ឍន៍សហគមន៍ ដូចជា BFD, CT, MODE និង អង្គការដទៃទៀតកំពុងចាប់ផ្តើមផ្ទេរការគ្រប់គ្រងនៃ សកម្មភាពខ្លះរបស់ពួកគេទៅដល់គណៈកម្មាការ របស់សហគមន៍។គណៈកម្មាការ អភិវឌ្ឍន៍ភូមិ (VDC) នៅតំបន់គោលដៅ របស់ KRDA កំពុងគ្រប់គ្រង គំរោងខ្លះរួចទៅហើយ។ KRDA ក៏បាន បណ្តុះបណ្តាលដល់គ្រូបណ្តុះបណ្តាល សុខភាពភូមិនៅក្នុងភូមិរបស់គេដែរ ដូចនេះបុគ្គលិករបស់ពួកគេអាចផ្លាស់ទៅ

តំបន់គោលដៅផ្សេងទៀត។ នៅពេលជាមួយគ្នានេះដែរអង្គការតូចៗជាច្រើនបានបញ្ជាក់ថាពួកគេ មិនទាន់បានគិតអំពីនិរន្តភាពរបស់កម្មវិធីនៅឡើយទេ ។ នៅតំបន់ទីក្រុងអង្គការដូចជា CWDA សហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដី នៅក្នុងគោលបំណងនៃការផ្ទេរការ គ្រប់គ្រងកម្មវិធីខ្លះទៅពួកគេហើយ USG ផ្តល់ការបណ្តុះបណ្តាលដល់សហគមន៍ សំណង់អាណាធិបតេយ្យនិងជួយពួកគេអោយមាន បណ្តាញការងារ។ ដូចនេះ ពួកគេអាចអនុវត្ត គំរោងបានដោយខ្លួន ពួកគេផ្ទាល់។

ដូចដែលបានបង្ហាញខាងលើសមាគមនិស្សិត KSIA ពឹងផ្អែកទៅលើការជួយគាំទ្រពីសមាជិកភាពប៉ុន្តែវាហាក់ដូចជាមាន ការជួយគាំទ្ររយៈពេលយូរ ពីសមាជិកដែលជា គ្រូបង្រៀន ធ្វើអោយ KSIA ជាអង្គការមួយគួរអោយចាប់ អារម្មណ៍ដើម្បីតាមដាន មើលនៅពេលអនាគត។

ជាទូទៅអង្គការផ្អែកបណ្តុះបណ្តាលកំពុងព្យាយាមធានានូវនិរន្តភាពកម្មវិធីរបស់ពួកគេដោយពង្រីកកម្មវិធី និង វិគ្គបណ្តុះបណ្តាល ថ្មីៗដើម្បីដោះស្រាយ ទៅនឹងការិតកើន ឡើងនៃ សមត្ថភាពគ្រប់គ្រង នៅកម្ពុជា។

## សន្និដ្ឋាន

និរន្តភាពរបស់កម្មវិធី-មិនមែនគ្រាន់តែនិរន្តភាពហិរញ្ញវត្ថុរបស់អង្គការប៉ុណ្ណោះទេ-កំពុងតែក្លាយជាការព្រួយបារម្ភយ៉ាងខ្លាំងសំរាប់អង្គការ ដែលមានភាពចាស់ទុំជាង នៅពេល ដែលពួកគេចាប់ផ្តើមយល់អំពី គោលគំនិតនេះ។ អង្គការដែលមានភាពចាស់ទុំ កំពុងចាប់ផ្តើមផ្ទេរសកម្មភាពទៅកាន់សហគមន៍ អង្គការតូចៗយល់ថា ពួកគេ ត្រូវការផ្តោតការយកចិត្តទុកដាក់ ច្រើនទៅលើ ទស្សនៈនេះប៉ុន្តែគេទទួលស្គាល់ថាពួកគេមិនស្ថិត នៅក្នុង តួនាទីនាពេលនេះដើម្បីពិចារណា លើបញ្ហានេះទេ។

## ៦.៨. ទស្សនៈវិស័យនិងការជំរុញភាពជាអ្នកដឹកនាំ

ដូចដែលការរំពឹងទុកនៃជំនាន់ដំបូងរបស់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា វាមិនមែនជាការភ្ញាក់ផ្អើលទេដែលថាស្ថាបនិក នៅបន្ត គ្រប់គ្រងអង្គការភាគច្រើននៅក្នុងការ របាយការណ៍ ឬ ពតិមាន (Portfolio) របស់ Pact ។ នៅក្នុងសង្គមកម្ពុជាពីបូរាណកាលពឹងផ្អែកទៅលើប្រព័ន្ធឋានានុក្រម ខ្ពស់មួយ ។ដូចនេះដើម្បីអោយ

អង្គការទាំងនេះនៅបន្តជាអង្គការសកម្មទៅអនាគត ភាគច្រើននឹងពឹងផ្អែកទៅលើសមត្ថភាព នៃអ្នកដឹកនាំដែលនឹងចែករំលែក ទស្សនៈរបស់ខ្លួនជាមួយបុគ្គលិក និង ជំរុញអោយមានភាពជាអ្នកដឹកនាំថ្មី ។ សំរាប់ហេតុផលនេះ យើងបានសំរេចចិត្តមើលទៅលើ ប្រធានបទទាំងពីរ នេះ។

ទាក់ទង ទៅនិង ទស្សនះវិស័យយើងបានរកឃើញថា អង្គការ ១៨ ក្នុងចំណោម អង្គការ ៣២ មានទស្សនះវិស័យទូលំទូលាយជាមួយនឹងលទ្ធផលនៃការផ្លាស់ប្តូរនិងធ្វើអោយប្រសើរឡើងនូវស្ថានភាពទូទៅនៅកម្ពុជា។ អង្គការ ៤ ផ្តោតការយកចិត្តទុកដាក់ទៅលើការ ធ្វើអោយប្រសើរឡើងស្ថានភាពរបស់ប្រជាជននៅសហគមន៏គោលដៅរបស់ពួកគេហើយអង្គការ ៥ ទៀតបាន ពិពណ៌នាអំពីទស្សនះវិស័យដែលទាក់ទងទៅនិងការបង្កើនគុណភាពការងារនិងកម្មវិធីនៃអង្គការរបស់ពួកគេ[៦] ។ នៅពេលដែលការសង្កេតមានការ លំបាកក្នុងការកំណត់បរិមាណវាលិចឡើងថា អង្គការដែលមានភាពចាស់ទុំមានទស្សនះផ្តោតត្រង់ទៅលើការបង្កើនសេវាកម្មរបស់ពួកគេហើយក្លាយជាអង្គការដែលរៀនសូត្រជាជាងទស្សនះមួយដែលរួមចំណែកយ៉ាងទូលំទូលាយទៅលើការអភិវឌ្ឍន៏កម្ពុជា។

*នាយកអង្គការ ស្តារកម្ពុជា ជាមនុស្សស្ងាត់ស្ងៀម ហើយយល់ស៊ីជំរៅ។ នៅពេល បុគ្គលិកមានកំហុស គាត់អញ្ជើញ បុគ្គលិកមកបន្ទប់ របស់គាត់ហើយផ្តល់ ដំបូន្មាន ដាច់ដោយឡែក ពីគ្នា។ ទស្សនះ របស់គាត់ គឺអនុញ្ញាតិអោយបុគ្គលិកធ្វើការដោយខ្លួនគេហើយមានកំហុសហើយគាត់អាចកែពួកគេនៅពេលក្រោយ។*

ការជំរុញអោយមានភាពជាអ្នកដឹកនាំគឺជាមធ្យោបាយមួយផ្សេងទៀតដើម្បីធានានូវ ការអភិវឌ្ឍន៏និងភាពចាស់ទុំរបស់អង្គការ។ ដើម្បី ប៉ាន់ប្រមាណថា តើអង្គការ ជំរុញភាពជាអ្នក ដឹកនាំក្នុងចំណោមបុគ្គលិក កម្មវិធីនិងអ្នកគ្រប់គ្រងថ្នាក់កណ្តាល យើងបានផ្តោតទៅលើក៏រិតដែលការដឹកនាំត្រូវបានផ្ទេរសិទ្ធទទួលខុសត្រូវជាពិសេសការទំនាក់ទំនង ជាមួយម្ចាស់មូលនិធិនិង ថាតើក៏រិតណាដែលអង្គការបានផ្តល់ឱកាសសំរាប់ការអប់រំនិងការធ្វើដំណើរទៅក្រៅប្រទេសដល់បុគ្គលិក។ ជាទូទៅយើងបាន រកឃើញថា ២១ អង្គការកំពុងខិតខំ ប្រឹងប្រែងផ្ទេរសិទ្ធិទទួលខុសត្រូវពីលើចុះក្រោម ជាពិសេសការផ្តល់អំណាចនិងលើកទឹកចិត្តបុគ្គលិកអោយមានបណ្តាញការងារជាមួយ ម្ចាស់មូលនិធិ ។ អង្គការ ៨ នៃអង្គការទាំង ៣២ បានបង្ហាញថាពួកគេមិនទាន់បានអនុវត្ត នៅឡើយទេ។

---

[៦] : យើងមិនបានប្រមូលពត៌មានអំពីទស្សនះវិស័យរបស់អង្គការ ៥

ទាក់ទងទៅនឹងជំនាញភាសាអង់គ្លេសឬ វិគ្គបណ្តុះបណ្តាល  អង្គការ ១៧ ក្នុងចំណោម អង្គការទាំង ៣២ បាន និយាយថានេះជាអាទិភាពរបស់ពួកគេហើយថ្វីបើបុគ្គលិកមួយភាគធំនិយាយអង់គ្លេស ហើយក៏ដោយក៏ពួកគេត្រូវបានចុះឈ្មោះរៀន  ភាសាអង់គ្លេសទៀតដែរ។ ក៏ដូចជា  បុគ្គលិកចេញទៅធ្វើទស្សនៈកិច្ចសិក្សាទៅលើគំរូនៃការអភិវឌ្ឍន៏ផ្សេង១និងជំនាញទំនាក់ទំនងទូទៅយើងគិតថាវាមានសារៈសំខាន់ដើម្បីស្វែងរកថាតើអង្គការកំពុងជំរុញអោយបុគ្គលិកធ្វើដំណើរចេញទៅក្រៅប្រទេសដែរឬទេ។ យើងបានបែងចែក  អង្គការមិនមែនរដ្ឋាភិបាលជា៣  ក្រុមអាស្រ័យទៅតាម  ចំនួនបុគ្គលិកហើយយើងបានសង្កេតឃើញថា  មិនមានភាពខុសគ្នាច្រើនទេ រវាងក្រុមនីមួយ១ :

- ២៩% នៃ បុគ្គលិកនៅ  ក្នុងអង្គការ  តូច ៨ (បុគ្គលិកតិច  ជាង ១០នាក់) បានធ្វើដំណើរ  ទៅបរទេស។ នៅក្នុងក្រុម  នេះស្ថិតនៅ  រវាងពី0 និង ១00% នៃបុគ្គលិកដែលបានធ្វើដំណើរ ទៅបរទេស។
- ៣១% នៃអង្គការ  មធ្យម (បុគ្គលិកលើសពី ២៨នាក់) ធ្វើដំណើរទៅបរទេស។ នេះ គឺខ្ពស់ ៧៥% នៃបុគ្គលិកបានធ្វើដំណើរទៅ  បរទេសពីអង្គការ មួយ។
- ៣0% នៃបុគ្គលិកនៅក្នុង  អង្គការធំ ៩ (បុគ្គលិក ២៥នាក់ឬ លើសពីនេះ) បានធ្វើដំណើរ ទៅបរទេស។ នេះស្ថិតនៅពីរវាង ៣% ទៅ ៥0%។

តាមតួលេខនេះយើងអាចឃើញថាមិនទាក់ទងទៅនឹងទំហំអង្គការទេ អង្គការមួយមានឳកាសធ្វើទស្សនៈកិច្ចសិក្សាទៅបរទេសជាងអង្គការមួយទៀត។ នេះចោទជាសំនួរថា  តើម្ចាស់មូលនិធិជួយគាំទ្រទស្សនៈកិច្ចសិក្សានៅបរទេសនិង  ការផ្តល់ដល់ដៃគូនូវធនធាន  ស្មើគ្នាដែរឬទេ សំរាប់សកម្មភាពទាំងនេះ។

## សន្និដ្ឋាន

នៅក្នុងការកំណត់ព្រំដែននៃ  ការសិក្សានេះ  វាមិនមានលទ្ធភាពដើម្បីពិនិត្យមើល ទំនាក់ទំនងរវាងស្ថេរភាពនៃមូលដ្ឋានផ្តល់មូលនិធិនិង  ចរិតលក្ខណៈរបស់អង្គការដែល  បានពិភាក្សានៅក្នុងផ្នែកនេះដើម្បីជំរុញភាពជាអ្នកដឹកនាំទេ។  ប៉ុន្តែយើងសង្ស័យថា  ជំនាញភាសាអង់គ្លេសមានសារសំខាន់ណាស់ចំពោះសមត្ថភាព  NGO មួយធានានូវការផ្តល់មូលនិធិដូចដែលបានបង្ហាញថាអង្គការផ្នែកអភិវឌ្ឍន៏សហគមន៏ជំនាញភាសាអង់គ្លេសនៅមានកំរិតជាហេតុធ្វើអោយមានការលំបាក  ក្នុងការធានានូវការផ្តល់មូលនិធិហើយ  កំរិតនៃការ  ផ្តល់មូលនិធិកំពុងធ្លាក់ចុះ   ។  ទាក់ទងទៅនឹងការធ្វើដំណើរទៅបរទេសនិងទស្សនកិច្ចសិក្សា  យើងបានកត់សំគាល់ថាអង្គការដូចជា USG និង ADHOC ជាទូទៅត្រូវបាន  ពិចារណាក្នុងចំណោម  អង្គការដែលមាន  ជោគជ័យ

បំផុតនៅកម្ពុជាមានសមាមាត្រខ្ពស់ ដែលបុគ្គលិកបាន ធ្វើដំណើរទៅបរទេសហើយ មានការកើនឡើងនៃការផ្ទេរ សិទ្ធិ ទទួលខុសត្រូវទៅដល់បុគ្គលិករបស់ពួកគេ ។

## ៦.៩. ធាតុដែលនាំអោយមានជោគជ័យ

យើងបានសំណូមពរដល់អង្គការទាំងអស់អោយផ្តល់នូវការយល់ដឹងរបស់ពួកគេទៅក្នុងអ្វីដែលពួកគេបានគិតថាជាមូលហេតុសំរាប់ការមានជោគជ័យនិងបានបន្តភាពដែលអាចសំរេចបាននេះ ។យើងសរុបចំលើយហើយសង្ខេបដូចខាងក្រោម :

- **ការគ្រប់គ្រងទូទៅ :** ការឆ្លើយជាដំបូងទាក់ទងទៅនឹងការគ្រប់គ្រងទូទៅ ។ អង្គការដែលបានសំភាសន៍បញ្ជាក់ថាគំនិតសំខាន់នៃ ជោគជ័យគឺត្រូវតែមានការគ្រប់គ្រងល្អ អ្នកដឹកនាំមានសមត្ថភាពនិងមានការប្តេជ្ញាចិត្ត មានការធ្វើផែនការ ច្បាស់លាស់ គោលនយោបាយនិង ការពិពណ៌នាអំពីការងារនិង តម្លាភាព ។ ចរិតលក្ខណៈដទៃទៀត បានបង្ហាញរួម ទាំងគុណភាពនៃសេវាកម្មនិង ការរៀបចំថវិការយ៉ាងប្រុងប្រយ័ត្ន ដែលឆ្លុះបញ្ចាំងអំពីសេចក្តីត្រូវការរបស់កម្មវិធីជាក់ស្តែង ។

- **គុណភាព សមត្ថភាពនិងបទពិសោធន៍របស់បុគ្គលិក:** ចំលើយរួមភាគច្រើនបំផុតបន្ទាប់ពីការគ្រប់គ្រងល្អ គឺតំរូវអោយមានបុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រាន់និងមានបទពិសោធន៍នៅក្នុងវិស័យដែលគេទទួលខុសត្រូវ ។ នេះរួមបញ្ចូល ទាំងគំនិតច្នៃប្រឌិត និងសមត្ថភាពនៃការអនុវត្តគំរោង ។

- **ការប្តេជ្ញាចិត្តរបស់បុគ្គលិក :** ស្មើរតែសំខាន់ ដូចសមត្ថភាពបុគ្គលិកដែរ គឺការប្តេជ្ញាចិត្ត របស់បុគ្គលិក ។ នេះរួមបញ្ចូល ទាំងការលើកទឹកចិត្ត ភាពស្មោះត្រង់ ភាពជឿទុកចិត្តនិង ភាពពេញចិត្ត ការងារ ។

- **ការចូលរួមរបស់សហគមន៍ :** បន្ទាប់ពីការប្តេជ្ញាចិត្ត របស់បុគ្គលិកចំលើយរួមភាគច្រើនបំផុតគឺសមត្ថភាពរបស់ NGO ដើម្បីធ្វើអោយមានការចូលរួម របស់សហគមន៍និង សមត្ថភាពសហគមន៍ ដើម្បីទទួលយកនូវតួនាទីដ៏សំខាន់នៅក្នុងការធ្វើផែនការ ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យសកម្មភាពកម្មវិធី ។ ការជឿជាក់ទៅលើ NGO ត្រូវបានដកស្រង់ថាជាគំនិតមួយនៃការធ្វើអោយមានការចូលរួមរបស់សហគមន៍ ។

- **បណ្តាញការងារ :** បណ្តាញការងារជាមួយម្ចាស់មូលនិធិនិងអាជ្ញាធរដែនដីនិងការចូលរួមរបស់សហគមន៍ គឺមានសារៈសំខាន់ ។ NGOs មួយចំនួនបានបញ្ជាក់ថា ផ្នែកដែលជាជោគជ័យរបស់ពួកគេទាក់ទងទៅនឹងការធានាអោយម្ចាស់ មូលនិធិផ្តល់ថវិកាគ្រប់គ្រាន់ទៀងទាត់ជួយគាំទ្រពី ម្ចាស់មូលនិធិធំៗហើយអាស្រ័យដោយ

ការជឿជាក់របស់ម្ចាស់ជាមូលនិធិនៅក្នុង ភាពជាអ្នកដឹកនាំរបស់ NGO ។ ការផ្តល់យោបល់មួយដ៏មានសារៈសំខាន់ NGO មួយកំណត់ជោគជ័យថាជាផ្នែកមួយនៃការនិយាយពីមាត់មួយទៅមួយរបស់ម្ចាស់មូលនិធិទៅម្ចាស់មូលនិធិដទៃទៀត ។ យោងទៅតាម អង្គការដែលបានសំភាសន៍ បណ្តាញការងារជាមួយ អាជ្ញាធរមូលដ្ឋានត្រូវបានពិចារណាថាមានសារៈសំខាន់ដូចជាបណ្តាញការងារជាមួយម្ចាស់មូលនិធិដែរ ដើម្បីជួយគាំទ្រដល់តំរូវការរបស់អាជ្ញាធរក្នុងការអនុវត្តកម្មវិធីដូចជា ការអប់រំសិទ្ធិមនុស្សដល់យោធានិងប៉ូលីស ។

- **ការរៀបចំកម្មវិធីនិង ការអនុវត្ត :** ជោគជ័យរបស់សកម្មភាពកម្មវិធី ពឹងផ្អែកទៅលើសមត្ថភាព របស់ NGO ដើម្បីតំរូវទៅនឹងសេចក្តីត្រូវការពិតប្រាកដ របស់សហគមន៍ ។ ចំពោះអង្គការសមាជិកភាពនិងអង្គការផ្តល់សេវាកម្មគឺតំរូវទៅតាមសេចក្តីត្រូវការសំរាប់សេវាកម្មឬការផ្តល់ការបណ្តុះបណ្តាលជំនាញដែលអាចជាតំរូវការខ្ពស់ ។ទស្សនៈសំខាន់ដទៃទៀតនៃការអនុវត្តកម្មវិធីរួមមានការធ្វើការប៉ាន់ប្រមាណអោយបានស៊ីជំរៅអំពីតំរូវការមុនពេលចាប់ផ្តើមគំរោងនិងធ្វើការប្តេជ្ញាចិត្តធ្វើការតាមដានគំរោងបន្ទាប់ពីគំរោងត្រូវបានបញ្ចប់និងស្វែងយល់ពីភាពបរាជ័យរបស់វា ។

- **ការងារជាក្រុម :** មានតែ NGO ពីរឬបី ប៉ុណ្ណោះបាន បង្ហាញពីសារៈប្រយោជន៍ នៃការងារជាក្រុម និងសាមគ្គីភាព ជាក្រុម ។ នៅក្នុងគំនិតរបស់ពួកគេគឺថា អង្គការដែលអាចដោះស្រាយបញ្ហាបាន ហើយមានការឯកភាពជាក្រុម មាន ឱកាសល្អជាងសំរាប់ភាព មានជោគជ័យ ។ យោបល់ដ៏ល្អមួយគឺថា ចរិតលក្ខណៈនៃការជឿជាក់ថាដំណោះស្រាយមួយអាចដោះស្រាយចំពោះរាល់បញ្ហា ។

- **កត្តាផ្សេងទៀត :** ជាបញ្ចប់ NGO ពីរឬបី បានបង្ហាញថាពួកគេ បានរៀនសូត្រច្រើនពីការ ចែករំលែកបទពិសោធន៍ជាមួយអង្គការ ដទៃទៀត ។ អង្គការខ្លះបានទទួលជំនួយ បច្ចេកទេសសំខាន់ៗ ហើយជួយគាំទ្រពីខ្មែរនៅបរទេសហើយអង្គការមួយបានបង្ហាញថា អង្គការកំពុងទទួលបានជោគជ័យដោយសារ NGO កំពុងមានថាមពលនៅក្នុងបរិយាកាសជាទូទៅ ។

## ៧‿ ការជួយគាំទ្ររបស់ Pact

អង្គការចំនួន ២២ ដែលយើងបានសំភាសន៍ បានបញ្ជាក់នូវការកោតសរសើរចំពោះ ការខិតខំប្រឹងប្រែងរបស់ Pact ទៅលើការផ្តល់ផ្នែកពង្រឹងសមត្ថភាព ។ វិស័យសំខាន់ៗដែលគេបានបង្ហាញរួមមាន :

- ការសរសេរសំណើ
- ការធ្វើផែនការ

- ការធ្វើផែនការយុទ្ធសាស្ត្រ
- ការរៀបចំគំរោង
- ការសរសេររបាយការណ៍

អង្គការ១៤បានបញ្ជាក់ពីការកោតសរសើរចំពោះការផ្តល់មូលនិធិរបស់ Pact ប្រសិនបើគ្មានមូលនិធិទាំងនេះ ទេវាមិនអាច អោយ NGOs របស់ពួកគេអនុវត្តសកម្មភាពបានទេព្រមទាំងការពង្រឹង អង្គការរបស់ពួកគេ។ អង្គការ៩បានកោតសរសើរខ្ពស់ចំពោះប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុការបណ្តុះបណ្តាលផ្នែក គណនេយ្យនិងអង្គការមួយចំនួន បានបញ្ជាក់ថាពួកគេបានប្រើ ប្រព័ន្ធហិរញ្ញវត្ថុបង្កើតឡើង ដោយ Pact ជាមួយម្ចាស់មូលនិធិដទៃទៀតដោយគ្មានបញ្ហា។

អង្គការ ៣ បាននិយាយថាការផ្តល់អោយនូវ អ្នកស្ម័គ្រចិត្តឬទីប្រឹក្សា បានជួយច្រើនចំពោះពួកគេ ។ ម្នាក់ក្នុងចំណោមអ្នកទាំងអស់នោះ គឺជាទីប្រឹក្សាហិរញ្ញវត្ថុ និង ម្នាក់ទៀតជា គ្រូបណ្តុះបណ្តាលផ្នែកអភិវឌ្ឍន៍សហគមន៍។ ម្យ៉ាងទៀត អង្គការមួយបានកោតសរសើរចំពោះ ការខិតខំប្រឹងប្រែងរបស់ Pact ដើម្បីជួយបុគ្គលិករបស់គេស្វែងរកការធ្វើកម្មសិក្សាជាមួយអង្គការផ្សេងៗ។

មធ្យោបាយដទៃទៀតដែល Pact បានជួយរួមចំណែកទៅដល់ដៃគូរបស់ពួកគេរួមមាន :

- ជួយគាំទ្រផ្នែកសន្និសិទនិងបណ្តាញការងារតាមខេត្ត
- រៀបចំការប្រជុំដៃគូនៅ Pact
- ផ្តល់ការពង្រឹងលើ ផ្នែកគ្រប់គ្រងនិង អង្គការ (រួមបញ្ចូលការ បណ្តុះបណ្តាល ទៅលើការប៉ាន់ប្រមាណសមត្ថភាពអង្គការ)
- ចរចានៅពេលមានទំនាស់របស់អង្គការដៃគូ

Pact ក៏បានជួយលើកលើក NGO ផងដែរ (ឧទាហរណ៍ នៅឯសន្និសិទផ្សេងៗ) ហើយណែនាំ ពួកគេទៅដល់ម្ចាស់មូលនិធិដទៃទៀត។ សិក្ខាសាលាអំពីទិសដៅអនាគតនិងសិក្ខាសាលាអំពីការស្វែងរកមូលនិធិរៀបចំដោយ Pact នៅឆ្នាំ ១៩៩៨ និង ១៩៩៩ គឺមានសារសំខាន់ចំពោះដៃគូ។

ជាបញ្ចប់ Pact ត្រូវបានសរសើរដោយអង្គការមួយសំរាប់ការជួយពង្រឹងផ្នែកភាពជាអ្នកដឹកនាំហើយជួយដៃគូ

អោយរៀនវិភាគទៅលើកម្មវិធីរបស់ពួកគេនិងកំណត់ចំណុចខ្លាំងនិងចំណុចខ្សោយតាមរយៈដំណើរការនៃការវាយតំលៃ និងសកម្មភាព តាមដានត្រួតពិនិត្យ ។ យ៉ាងហោចណាស់ មានអង្គការ ដៃគូរ ២ បាននិយាយថា " Pact បានបង្រៀនយើងអោយក្លាយទៅជា NGO ពិត១ " ។

ស្ទើរតែទាំងអស់នៃ NGO ដែល Pact បានជួយគាំទ្រ ចន្លោះពីឆ្នាំ ១៩៩២ និង ២០០០ កំពុងបន្តសកម្មភាព ។ ពួកគេមិនមែនស្ថិតនៅក្នុងក្រុមតែមួយទៀតទេហើយកំពុងឈានទៅរកភាពរឹងមាំនិងជឿនលឿនទាំងនៅក្នុងវិស័យដូចគ្នានិងវិស័យផ្សេង១គ្នា ។ ខណៈពេល ដែលពួកគេកំពុងតែបន្តកើនឡើង នូវចំណេះដឹងនិងជំនាញនិរន្តភាពនៅពេលអនាគតរបស់ពួកគេ នឹងពឹងផ្អែកទៅលើ សមត្ថភាពរបស់ពួកគេដើម្បីប្រលងប្រជែងស្វែងរកធនធានដែលកំពុងផ្តោតតែទៅលើអង្គការតិចតួចនេះ ។ ធាតុសំខាន់១ មួយនៃនិរន្តភាពគឺជា សមត្ថភាពរបស់ពួកគេដើម្បីពង្រឹងឯករាជ្យភាព និងការផ្តួចផ្តើមរៀបចំ និងអនុវត្តគំរោងក៏ដូច ជាការជួយគាំទ្រពីសហគមន៍មូលដ្ឋានរបស់ពួកគេផងដែរ ។

# ៨. ឧបសម្ព័ន្ធ

## ៨.១. បញ្ជីឈ្មោះអង្គការដែលបានសំភាសន៍

| ពាក្យកាត់ | ឈ្មោះអង្គការពេញ |
|---|---|
| 1. ADHOC | សមាគម អាដហុក, ការពារសិទ្ធ មនុស្សនិង អភិវឌ្ឍន៍នៅកម្ពុជា |
| 2. BWAP | កម្មវិធីស្ត្រីអប់រំជម្ងឺអេដស៍ខេត្តបាត់ដំបង |
| 3. BFD | អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ |
| 4. CVCD | ខ្មែរស្ម័គ្រចិត្តដើម្បីអភិវឌ្ឍន៍សហគមន៍ |
| 5. CADET | សមាគមខ្មែរសាមគ្គីបង្កើនសេដ្ឋកិច្ចកម្ពុជា |
| 6. CMA | សមាគមឆ្មបកម្ពុជា |
| 7. CWDA | សមាគមអភិវឌ្ឍន៍ស្ត្រីកម្ពុជា |
| 8. CEPA | សមាគមថែរក្សាបរិស្ថាននិងវប្បធម៌ |
| 9. CHED | អង្គការអប់រំសុខភាព កម្ពុជាដើម្បីអភិវឌ្ឍន៍ |
| 10. CT | អង្គការ ជីវិតថ្មី |
| 11. VIGILANCE | អង្គការ រក្សាការពារ សិទ្ធិមនុស្សនៃ កម្ពុជា |
| 12. KNCED* | សហគមន៍ខ្មែរអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ |
| 13. KT | កសិករថ្មី |
| 14. KRDA | អង្គការអភិវឌ្ឍន៍ជនបទខ្មែរ |
| 15. KSA | សមាគមនិស្សិតជនបទខ្មែរ |
| 16. KSIA | សមាគមនិស្សិតខ្មែរ |
| 17. KOTTARAK | កុត្តរ: |
| 18. KWWA | សមាគមសុខមាលភាពស្ត្រីខេត្តក្រចេះ |
| 19. LICADHO | សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីការដូ |
| 20. MEDICAM | អង្គការមេឌីខាំ |
| 21. MODE | សមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ |

| | |
|---|---|
| 22. ML | ម្ដាយនៃក្ដីសង្ឃឹម |
| 23. OUTREACH | អង្គការកម្ពុជាដើម្បីអភិវឌ្ឍន៍និងលើកស្ទួយសិទ្ធិ |
| 24. PLK | ពន្លឺខ្មែរ |
| 25. RACHANA | រចនា |
| 26. RUFADE* | អង្គការ រូហ្វាត |
| 27. RDA* | សមាគមអភិវឌ្ឍន៍ស្រុកស្រែ |
| 28. SABORAS | សប្បុរស |
| 29. SAMAKEE | សាមគ្គី |
| 30. SILAKA* | សីលការ |
| 31. SSC | អង្គការសេវាសង្គមកិច្ចកម្ពុជា |
| 32. SEDOC | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកម្ពុជា |
| 33. STAR | ស្ដារកម្ពុជា |
| 34. USG | គណៈកម្មធិការសំរបសំរួលអភិវឌ្ឍន៍ទីក្រុង |
| 35. VBNK | វិទ្យាស្ថានបណ្ដុះបណ្ដាលអ្នកគ្រប់គ្រងការងារអភិវឌ្ឍន៍ |
| 36. WFP | អង្គការចំរើនស្ត្រី |

*យោងទៅតាមផលលំបាកនៃពេលវេលានិងកាលវិភាគយើងមិនបានរៀបចំទិន្នន័យ អោយពេញលេញចំពោះអង្គការទាំងនេះបានទេ។ ដូចនេះអង្គការទាំងនោះ  មិនបានរាប់បញ្ចូលទៅក្នុងការវិភាគនៃអង្គការ  ទាំង៣២ នេះទេ។